យប់នោះ ព្រះច័ន្ទអណ្តែតនៅក្នុងលំហមេឃ លេចរូបរាងតែមួយភ្លែតតាមចន្លោះផែនពពក រួចក៏កប់បាត់ទៅវិញ ។ ផ្ទៃមេឃពាសផាសទៅដោយពពកខ្មៅ ហាក់ដូចជាចង់ស្រក់គ្រាប់ភ្លៀង ។ បូរិន្ទនិងនាងសម្ផស្សនាំគ្នាស្ពាយបង្វេចចុះពីផ្ទះ ធ្វើដំណើរកាត់ព្រៃចេកទៅកាន់មាត់ទន្លេ ក្នុងភាពងងឹតស្ងងស្ងប់ ។ ក្នុងដំណើរនេះ គេមិនហ៊ាននិយាយស្តីរកគ្នាឱ្យលេចឮសំឡេងឡើយ ។

កាលទៅដល់មាត់ទឹក បូរិន្ទស្រាយកូនទូករបស់ខ្លួន ដែលបានចងទុកអែបច្រាំងជាប្រចាំរាល់ថ្ងៃ យកមករៀបចំប្រញឹបប្រញាប់ ឱ្យនាងសម្ផស្សឡើងអង្គុយស្រួលបួល ហើយគេក៏ចាប់ច្រវាចែវចេញទៅ ។ ទៅដល់ពាក់កណ្តាលទន្លេ ទើបគេមានភាពកក់ក្តៅបន្តិចចាប់សន្ទនាគ្នាឡើង ៖

– បង . . . ( សម្ផស្សរាចាសួរតិច ៗ ) យើងគ្មានផ្លូវណាចេញក្រៅពីធ្វើដំណើរតាមទូកនេះទេឬ ?

– គ្មានទេអូន ផ្លូវគោកពួកទាហានយាមច្រើនណាស់!

– អញ្ចឹង យើងគិតឆ្លងទៅកន្លែងណា ?

– ហ៊ឺ . . . បងដូចជាងងឹតសូន្យតែម្តង . . . គិតថាបើយើងឆ្លងទៅត្រើយជិតនេះខ្លាចប៉ះខ្សែក្រវាត់ទាហានវដ្តការ . . . អូនជួយគិតបងផង ?

– ម៉េច អួតមកម្នាក់ឯង ឥឡូវពឹងខ្ញុំហើយឃើញទេ



– បើមិនឱ្យបងពឹងអូន តើទៅពឹងអ្នកឯណា ?

សម្ផស្សខំញញឹមកាត់ភាពងងឹតទៅរកមាណពចែវទូក ដើម្បីបំភ្លេចសេចក្តីទុក្ខព្រួយ ។

– បើប្រគល់ឱ្យខ្ញុំជាអ្នកនាំផ្លូវអញ្ចឹង សូមបងចែវទូកទៅតាមបណ្តោយទន្លេមេគុងនេះចុះតែទៅក្រោមទៅ ព្រោះទិសដៅយើងចេញពីទន្លេតូច ។

ឮដូច្នេះ បូរិន្ទខំបញ្ចេញកម្លាំងចែវគាស់យ៉ាងខ្មីត . . . ។ ទន្លេមេគុងស្ថិតនៅក្នុងរដូវទឹកកំពុងឡើងមានវិសាលភាពធំធេង ។ ខ្សែទឹកហូរសំរុកបុកខ្ទល់ខ្លាញ់ប្រដេញទៅកាន់ទីខាងក្រោម គួរឱ្យខ្លាច ។ ប៉ុន្តែចិត្តសង្សារមួយគូនេះ ដែលមានទុក្ខវេទនា ពុំអាចជ្រកកោននៅក្នុងរបបវដ្តការបានសុខចិត្តស្លាប់រស់ជាមួយគ្នា ពុះពារឆ្លងកាត់កណ្តាលភាពអន្ធការគ្មានខ្លាចញញើតនឹងការគំរាមកំហែងនៃធម្មជាតិឡើយ ។

ស្ថិតនៅក្នុងសភាពស្ងប់ស្ងាត់អស់ពេលដ៏យូរ សម្ផស្សក៏ចាប់បន្តរឿងសាជាថ្មី ៖

– បង . . . បងមានធ្លាប់ស្គាល់ភូមិណាមួយ ឬ ជនណាម្នាក់នៅក្នុងតំបន់រំដោះដែលយើងត្រូវទៅនោះទេ ?

បូរិន្ទដកដង្ហើមមួយខ្សែទើបឆ្លើយ ៖

– បងគ្មានដែលស្គាល់អ្នកណាសោះអូន ដូចបងធ្លាប់បានប្រាប់អូនថា បងធ្វើការតស៊ូគ្មានខ្សែរយៈទេ . . . បងកំពុងគិតថា រត់ចេញ

មកនេះគឺគ្រាន់តែគេចខ្លួនឲ្យរួចពីការជាប់គុកច្រវាក់ ហើយមានរំពឹងទៅលើអង្គការបដិវត្តន៍មូលដ្ឋាន ដើម្បីសុំជ្រកកោននិងសុំចូលរួមចំណែកធ្វើការតស៊ូរំដោះជាតិ...អូនជួយគិតមើល អង្គការរណសិរ្សទទួលស្គាល់បងទេ ?

– ចាស ! អង្គការរណសិរ្សជាអង្គការមួយប្រមូលផ្តុំកម្លាំងគ្រប់ស្រទាប់វណ្ណៈដើម្បីធ្វើការតស៊ូរំដោះជាតិ ... ពេលយើងចេញទៅដល់មូលដ្ឋានរំដោះ ច្បាស់ជានឹងត្រូវបានទទួលរាក់ទាក់ ។

– អូនធ្លាប់ចេញចូលតំបន់រំដោះ បានដឹងរឿងនេះច្បាស់មែនទេ ?

– ចាស !..

– អូនធ្លាប់បានរួមចំណែកក្នុងការធ្វើសង្គ្រាមរំដោះជាតិ យូរមកហើយបើអញ្ចឹង ?

– ចាស !..

– អូននិយាយប្រាប់បងសាឡើងវិញមើល ពីប្រវត្តិគ្រួសារឪពុកម្តាយរបស់អូន ... មូលហេតុអ្វីបានជាមានការឈឺចាប់ចូលរួមចលនាតស៊ូរំដោះជាតិ ?

សម្តស្សនឹកថា ក្នុងរយៈកាលកន្លងមក នាងពុំទាន់ប្រាប់ប្រវត្តិគ្រួសារឪពុក ម្តាយរបស់នាងឲ្យបុរិន្ទដឹងច្បាស់លាស់ទេ បុរិន្ទបានដឹងរឿងនាងដោយសារការរៀបរាប់របស់អ៊ិស្ហនប៉ុណ្ណោះ ។ ពេលនេះនាងមិនត្រូវលាក់លៀមនឹងបុរិន្ទតទៅទៀតឡើយ ។



ចាស គ្រួសារឪពុកម្តាយរបស់ខ្ញុំមានទីលំនៅៗភូមិកោះកែវ... ម្តាយខ្ញុំស្លាប់នៅឆ្នាំ ១៩៧២ ដោយសារគ្រាប់កាំភ្លើងបាញ់ពីកម៉ាល់ប្រយុទ្ធរបស់ពួករដ្ឋការ – អាយ៉ងធិវគី .. ខ្ញុំរស់នៅជាមួយឪពុក ខំរកស៊ីចិញ្ចឹមជីវិតដោយចេញចូលទៅដោះដូរស្រូវ អង្ករពីក្នុងតំបន់រំដោះមកសំរាប់ផ្គត់ផ្គង់ជីវភាព ។ ពេលនោះ ឪពុករបស់ខ្ញុំក៏មានទំនាក់ទំនងជាមួយអង្គការរណសិរ្សរួបរួមជាតិយ៉ាងជិតស្និទ្ធគាត់ក៏ត្រូវបានអង្គការនោះទទួលស្គាល់ និងបំពាក់ជំហរស្មារតីឲ្យចូលរួមចំណែកធ្វើសង្គ្រាមរំដោះជាតិ ។ កន្លងមកគាត់និងខ្ញុំបានយកអស់កម្លាំងកាយចិត្ត ជួយដឹកជញ្ជូនស្បៀង គ្រាប់រំសេវមកកាន់សមរភូមិច្រើនលើកច្រើនសា ហើយបានថែរក្សាការសម្ងាត់ជូនបដិវត្តន៍បានយ៉ាងល្អបំផុត។ ប៉ុន្តែថ្ងៃជន្ម យប់មួយនោះដែលឪពុកខ្ញុំ និងខ្ញុំបញ្ជូនទ័ពមកកាន់ត្រើយស្ពានៅក្នុងស្រុកលើកដែកប្រទះនឹងពួកទាហានរដ្ឋការ. .ពួកគេរត់អស់ទៅ នៅសល់តែគាត់និងខ្ញុំត្រូវវាចាប់មក ហើយក៏បែកបាក់គ្នារហូតណាំបង !

– សម្តស្ស... ( បុរិន្ទពោលឡើងក្នុងក្តីសង្ស័យ ) បងយល់ថាអូនមានខ្សែរយៈតស៊ូ .. ទៅដល់តំបន់រំដោះច្បាស់ជារដ្ឋអំណាចបដិវត្តទទួលស្គាល់យើងមិនខាន ។

– ចាស ខ្ញុំក៏នៅមានសង្ស័យខ្លះ.. ប៉ុន្តែពុំហ៊ានសន្និដ្ឋានថាយ៉ាងណាទេ ព្រោះសភាពការណ៍តែងមានការប្រែប្រួលពីដំណាក់ការមួយទៅដំណាក់ការមួយទៀត ។

ក្នុងខណៈដែលអ្នកទាំងពីរបានពិភាក្សាគ្នាមកដល់ត្រឹមនេះ ស្រាប់តែមានពន្លឺភ្លើងហ្វាយ៉ាងធំ បញ្ចាំងចេញមកពីកប៉ាល់ប្រយុទ្ធរបស់កងទ័ពជើងទឹក ដែលបោះទីតាំងនៅឯទន្លេបួនមុខ ។ ពន្លឺនោះជះកាំរស្មីឆ្វាចចុះឆ្វាចឡើងពាសផ្ទៃទន្លេ ។

បូរិន្ទឧទានញាប់ៗ ៖

– អូនសម្ផស្ស ! . . . ពួកទាហានជើងទឹកបញ្ចាំងភ្លើងមកចំយើងហើយ ។

– យីបង !.. គិតយ៉ាងម៉េចទៅ ? សម្ផស្សបន្លឺដោយភិតភ័យ ។

– អូន ! យើងក្រាបឱ្យរាបទៅលើរនាបទូក កុំងើបណា៎ យើងឥតមានមធ្យោបាយណាអាចគេចខ្លួនរួចទេ បើសិនជាពួកវាឃើញយើង... ។

បូរិន្ទពោលព្រមទាំងខំរង្គោះដកដងថែវចេញ ។ គេក៏ក្រាបនៅជិតសម្ផស្សហើយខំរវ្ភែកមើលទិដ្ឋភាពជុំវិញទូករបស់ខ្លួន ។ គាប់ជួនពេលនោះ មានសំណាត់កំប្លោកវែងៗអណ្តែតមកគរពួនជាច្រើន ។ ស្ថិតនៅមិនឆ្ងាយប៉ុន្មាន បូរិន្ទខំកាយទឹកបញ្ជូនទូកឱ្យទៅដល់សំណាត់ទាំងនោះ ។ បូរិន្ទ អែបទូកជាប់នឹងគំនរកំប្លោក រួចទាញខ្សែមួយចង្វាយនាំសម្ផស្សចាប់គុម្ពកំប្លោកចងរាយព័ទ្ធជុំវិញទូក និងលើករាគរលើក្បាលខ្លះ កន្ទុយខ្លះ ។ សព្វគ្រប់ហើយគេនាំគ្នាសម្ងំដេកទាំងពីរនាក់ បណ្តោយឱ្យវារសាត់អណ្តែតទៅតាមកម្លាំងទឹកហូរដោយឯងៗ ។



មិនយូរប៉ុន្មាន គេបានឮស្នូរសំឡេងជលយានយន្តមួយ ដែលប្រើ ាយកម្លាំងគ្រឿងចក្រយ៉ាងធំ បើកចេញមកលាន់គគ្រឹក ហាក់ដូចជា ប់ហែកផ្ទៃមេគុង ឱ្យបែកជាពីរបីផែនដាច់ចេញពីគ្នា ។

– កងម៉ារីន វាចេញល្បាតហើយ !

បូរិន្ទឱ្យបដាក់ត្រចៀកសម្ផស្ស ។ សម្ផស្សចាប់ញ័រចំប្រប់ដូចកូន ត្រូវគ្រវភ្លៀងខ្យល់ ។

– បង ! យើងច្បាស់ជាចៀសមិនរួចពីគ្រោះថ្នាក់ទេ !

– ទ្រាំសម្ងំតាមយថាកម្មទៅអូន ..អម្បាញ់មិញនេះ បើសិនជាវា នទាន់ឃើញយើងទេ ទោះបីវាមកជិតក៏មិនចាប់អារម្មណ៍លើទូកយើង ព្រោះសំណាត់កំប្លោកច្រើនណាស់ ! ។

បូរិន្ទងាកផៀងភ្នែក តាមសម្លឹងមើលជលយានយន្តរបស់ទាហាន ការជាប់ជានិច្ច ។ គេឃើញវា បើកបណ្តោយតាមមាត់ទន្លេពិនិត្យ ត្រើយខាងឆ្វេង ចេះតែរត់ឆ្ងាយទៅៗ អស់មួយសន្ទុះធំ ទើបឃើញ ត្រឡប់មកវិញសៀរត្រើយខាងស្តាំ ទីបំផុតក៏បោលចូលទៅកាន់កន្លែង វិញ ។

បូរិន្ទ និងសម្ផស្សនឹកអរព្រួច គិតថាខ្លួនបានរួចគ្រោះមួយគ្រា ។ រិន្ទងើបមើលនាយមើលអាយ រួចទាញនាងសម្ផស្សឱ្យក្រោកឡើង ងុយ សំរួលខ្លួនប្រាណឡើងវិញ ។ មេឃងងឹតឈឹប ឥតមានផ្កាយ

មួយគ្រាប់សោះ ។ ពពកខ្មៅឃ្មឹកពាសផ្ទៃអាកាស ហាក់ដូចជាពិតានគ្របដណ្ដប់លើមេកុងទាំងមូល ប៉ុន្តែមិនស្រក់ភ្លៀងទេ គ្រាន់តែទោរទន់ទៅតាមក្បាលទឹកឡើងប៉ុណ្ណោះ ។ ភាពអន្ធការបែបនោះ ពិតមែនតែជាបរិយាកាសមួយអាប់អួរបស់រាត្រីកាល តែជាអំណោយផលមួយល្អដែរសំរាប់គូជីវិតពីរនាក់នេះភៀសខ្លួន ។

បូរិន្ទចាប់ច្រវារៀបចំម្ដងទៀត ប្រឹងចែវជំរុញទូកឱ្យលឿនដើម្បីឆ្ងាយផុតពីទីគ្រោះថ្នាក់ ។

- បងគិតធ្វើអី ? ( សម្ផស្សប្រញាប់សួរ ) ។
- បងគិតស្រាយកំប្លោកចេញ ចែវទូកឡើងវិញ
- ទេ ! កុំអាលសិន ! . . អង្គុយមកវិញមក !
- ម៉េចបានជាអូនឃាត់ បងចង់នាំអូនចេញឱ្យបានឆាប់រហ័ស !
- ចាស ត្រូវហើយ ! តែកុំអាលទុកចិត្ត . .

សម្ផស្សទើបវាចាបានត្រឹមនេះ ស្រាប់តែមានសូរសំឡេងងឺត ។ នៅលើមេឃមកពីនាយ គឺជាស្នូរយន្តហោះ។ មិនយូរប៉ុន្មានលេចពន្លឺភ្លើងក្រហមភ្លែតៗ នៅលើអាកាសហើយក៏បានមកដល់ពីលើក្បាល ។ បូរិន្ទសង្កេតទៅឃើញរូបភាពយន្តហោះខ្មៅស្លុង គឺជាយន្តហោះធុនទ្រុងជ្រូករបស់ចក្រពត្តិអាមេរិក ។ យន្តហោះនោះ ផ្លែលបានមួយជុំ ក៏ចាប់ទម្លាក់ភ្លើងគោមប៉ុន ៗ ចង្អេរ រាយជាខ្សែនៅលើដងទន្លេបីដូចជាអំពូលអគ្គិសនីឆេះលើមេឃ ។



បូរិន្ទនិងសម្ផស្សប្រញាប់នាំគ្នាក្រាបសម្ងំតទៅទៀត ។ គេខំទាញស្លឹកកំប្លោកមកគ្របលើខ្លួនប្រាណ ដើម្បីកុំឱ្យពន្លឺភ្លើងគោមនោះចាំងលើខ្លួន ។

យន្តហោះទ្រុងជ្រូក ហោះពីរ បីបកក៏ចាប់បាញ់គ្រាប់មីត្រៃយ៉ើរចេញទាំងខ្សែ ៗ លាន់ស្នូរៗ ... ដូចគេបង្ហូរដុំថ្មតាមទរដែកពីកំពូលភ្នំ។ បូរិន្ទនិងសម្ផស្សស្រៀវឆ្អឹងខ្ទង់ខ្ទាក ៗ ខំយកដៃចុកត្រចៀកហើយចេះតែនឹកមមៃថា ជីវិតនឹងត្រូវដល់ទីបញ្ចប់នាពេលនេះ ! . . . គ្រាប់ធ្លាក់ដូចគេបង្ហូរមិនអាចជៀសរួចពីសេចក្ដីស្លាប់ទេ ! . . . ប៉ុន្តែមិនទាន់ដឹងត្រូវត្រង់ណា ក្បាលដងខ្លួនឬដៃជើង . . . ស្លាប់អង្កាល់ ? ស្លាប់ទៅឈឺយ៉ាងម៉េច ? គ្រប់វិនាទីគេនឹកឃើញតែសេចក្ដីស្លាប់ !

អស់រយៈមិនដឹងជា ប៉ុន្មានម៉ោង ប៉ុន្មាននាទី គេនៅតែឮស្នូរយន្តហោះនេះបាញ់មិនឈប់ឈរ ។ យូរៗទៅបូរិន្ទដូចជាស៊ាំនឹងការខ្លាចគេវែកស្លឹកកំប្លោកចោលភ្នែកទៅ ឃើញគ្រាប់ភ្លើងហូរជាខ្សែផះទៅលើដែនដីត្រើយខាងឆ្វេងតាមបណ្ដោយមាត់ទន្លេ ។ បូរិន្ទនឹកក្ដៅក្រហាយ "យី! អាយន្តហោះចក្រពត្តិចង្រៃនេះ! វាផ្ទុកគ្រាប់បានប៉ុន្មានកប៉ាល់ បានជាបាញ់រះមួយកំណាត់យប់ហើយមិនឆ្អែតមិនឆ្អន់? អាជម្ងឺឃ័ននេះប្រហែលជាវាចង់រំលាយមាតុភូមិកម្ពុជា ឱ្យក្លាយទៅជាហ៊ីរ៉ូស៊ីមា ឬក៏វាធ្វើបុណ្យអបអរសាទរខ្មោចម៉ែឪវា ! " ។

*

* *

# ៦

## វិនាសកម្ម

ប្រហែលម៉ោងប្រាំទៀបភ្លឺ ទូកតូចបានរសាត់ទៅដល់ជិតកោះ មួយ។ នាងសម្ផស្សក្រោកឡើងអង្គុយ យកដៃច្បូតសក់ រួចសម្លឹងមើល ទៅទិសខាងកើត ឃើញផ្ទៃមេឃប្រែពណ៌ឡើងស្លេះៗ ។ នាងយល់ ថានៅមិនយូរប៉ុន្មាន ព្រះអរុណនឹងរះឡើងមកបំភ្លឺលោកនេះហើយ ។ នាងលើកដៃអង្រួនបូរិន្ទ ដែលកំពុងដេកលក់ស្រមុកខ្វរ ៗ នៅក្បែរ នាង ។

បូរិន្ទ ចាប់ពីពេលឆ្លងផុតកន្លែងយន្តហោះទម្លាក់ភ្លើងបាញ់រះមក គេខំចែវទូកជំរុញដំណើររបស់ខ្លួន អស់ពីកម្លាំងកាយ ។ នរះទើបនឹង សំរាកបានក្នុងរយៈមួយម៉ោងប៉ុណ្ណោះ ។ ភាពប្រផាក់ស្រើតចេញពីផ្ទៃ ទឹកនិងខ្យល់ចុងរាត្រី ធ្វើឱ្យអ្នកសម្ងំលង់លក់ដូចគេស្រណុំ ។ សម្ផស្ស នឹកគិតដល់ការហត់នឿយយុវបុរសដែរ តែឱកាសបែបនេះ មិនអាច បណ្តោតបណ្តោយឱ្យទរៈសម្ងំដេកតទៅទៀតបាន ។ នាងយកដៃផាត់ សក់រួចឱនខ្សឹបផាក់ត្រចៀកបូរិន្ទតឿនឱ្យក្រោកឡើងផាញឹកញយថា :

" បង ក្រោកឡើង !.. ភ្លឺហើយ ... "



បូរិន្ទប្រែខ្លួនមើលមុខមាណវី រួចក្រោកអង្គុយទាំងសភាពងោក ។ គេក្បង់ទឹកលុបមុខ ជូតភ្នែកឱ្យស្រឡះ រួចមើលនាយអាយ ទៅសម្ផស្សថា :

- អូន ! យើងមកដល់កន្លែងណាហើយ អូនស្គាល់ទេ ?

- ចាស កំពុងតែពិនិត្យមើល ... ទិដ្ឋភាពនៅតាមដងទន្លេនេះ ដូចជាជិតដល់កោះកែរហើយបង !

- អុំ កោះកែរ ភូមិស្រុករបស់អូននោះឬ ?

- ចាស !..

សម្ផស្សចោលភ្នែកទៅឃើញកោះច្បាស់ ហើយនៅលើត្រើយ ឆ្វេងនាងចំណាំបានភូមិករ ក៏ឧទានឡើងភ្លាម :

- បង យើងមកដល់កោះកែរមែនណាបង !

បូរិន្ទឮដូច្នោះ ក៏ពោលឡើងទាំងអរកខឹបកខុប :

- អូន បងសប្បាយចិត្តណាស់ បានមកដល់ភូមិស្រុករបស់អូន ដូច្នេះយើងគិតយ៉ាងម៉េច ឆ្លងទៅរកផ្ទះអូនតែម្តងឬ ?

សម្ផស្សបន្ទីរាចាតបក្នុងការត្រិះរិះ :

- ចាសមកដល់ទីនេះហើយត្រូវចូលទៅផ្ទះ ប៉ុន្តែឪពុករបស់ខ្ញុំ មិនដឹងគាត់នៅរស់ឬស្លាប់ ...

- ទោះបីយ៉ាងណាក៏ដោយត្រូវចូលទៅសួរកគាត់ ( បូរិន្ទឱ្យ យោបល់ ) បងក៏ចង់ជួបមុខគាត់ដែរណាអូន ។

- ចាស ! អញ្ចឹងយើងឆ្លងទៅកាន់មាត់ច្រាំង សម្ងំនៅម្តុំខាងណោះសិនចាំដល់ពេលភ្លឺ មានប្រជាជនដើរហើរមកចំការ យើងសាកសួរពត៌មានបានច្បាស់លាស់ចាំនាំគ្នាចូលទៅភូមិ ។

- ម៉េចក៏ចាំធ្វើអញ្ចឹង ?

- យើងធ្វើដំណើរទៅតែម្តងមិនបានទេ ព្រោះសភាពការណ៍កន្លងមកខ្ញុំក្តាប់មិនបាន ក្រែងមានទាហានវដ្តការវាចូលទៅនៅក្នុងភូមិនោះ។

- ត្រូវហើយ អូនមានស្មារតីប្រុងប្រយ័ត្នខ្ពស់

បុរិន្ទនិយាយផង អុំទូកផង សំដៅកាន់មាត់ច្រាំងដែលនាងសម្ផស្សកំណត់យកទីឈប់សំរាក ។ ទៅដល់មាត់ច្រាំងនោះ បុរិន្ទចងទូកទុកមួយកន្លែង រួចនាំនាងឡើងទៅសំរាកនៅទីទួលខាងលើ ។ ទីនោះមានស្មៅខ្ពស់ ៗ មានកូនឈើដុះល្បោះ ៗ ល្មមលាក់ខ្លួនបំពួនអាត្មាបាន ។ គេនាំគ្នាសម្រាក រង់ចាំថ្ងៃរះឡើង នឹងចេញទៅពិនិត្យសភាពការណ៍ ។ តាមធម្មតាពេលថ្មើរនេះ ក្នុងភូមិតែងមានសភាពអ៊ូអរហើយ តែពេលនេះស្ងាត់សូន្យ ។

- បង ! ជួយស្តាប់គ្នាមើល នៅឯភូមិមានឮសំឡេងអ្វីទេ ?

- យីដូចជាស្ងាត់សូន្យតែម្តង សូម្បីសំឡេងឆ្កែព្រុសឬមាន់រងាវក៏គ្មានដែរ ..ម៉េចអញ្ចឹង ?

- ហ៊ី ..., មិនដឹងដែរបង ព្រោះខ្ញុំបានបែកឃ្លាតពីភូមិស្រុកនេះពីរខែហើយ មិនដឹងជាស្រុកទេសមានការប្រែប្រួលយ៉ាងណាទេ ?



បុរិន្ទអស់ពីអង្គុយ ក៏ក្រោកឈរដើរចុះដើរឡើង សម្លឹងមើលនាយមើលអាយ ក្នុងចិត្តដូចជាសាប់រសល់ ក្នុងការទន្ទឹងចាំពេលវេលាដែលនឹងនាំមកនូវព្រឹត្តិការណ៍ផ្សេងៗ ក្នុងថ្ងៃថ្មីនោះ ។ ខណៈនោះស្រាប់តែគេឮស្នូរសំឡេងគគ្រឹកនៅលើមេឃដ៏សែនខ្ពស់ គឺជាសំឡេងយន្តហោះប្រតិកម្ម! . ។បុរិន្ទងើបតាមសម្លឹងមើលឃើញខ្សែផ្សែងឆ្នូតៗ បី វែងដូចផាកនុយខ្លែងអូសឆូតមេឃ ហើយនៅខាងមុខមានចំណុចសៗបីរាងដូចផ្លែព្រួញ ..

" អ្ហឹះ ! យន្តហោះបេ ៥២ ! "

ជាមួយនឹងការឧទានរបស់បុរិន្ទ ស្រាប់តែគេឃើញវាហោះវង់ផ្លៀងមកឆ្វេង ។ បុរិន្ទកត់សំគាល់បាន ក៏ប្រញាប់ស្រែកឡើងស្លូន់ :

- អា !. មិនស្រួលទេអូនសម្ផស្ស ! យើងរកកន្លែងក្រាប រត់មកសម្ផស្ស ! រត់មកអូន !

បុរិន្ទប្រាសទៅរកច្រាំងទន្លេ សម្ផស្សខំស្ទុះតាមបានបួន ប្រាំជំហានស្រាប់តែមានសន្ធឹះសំឡេង រូ !.. រូត !.. រូត !. ដូចជារលំមេឃមកគ្របសង្កត់ នាងផ្តួលខ្លួនចូលរណ្តៅមួយ ហើយខំស្រែកស្លូន់ប្រាប់បុរិន្ទ :

- បងបុរិន្ទ !.. បងក្រាបទៅ ! ក្រាបទៅ ! យន្តហោះទម្លាក់គ្រាប់ហើយ !..

សាហាវអស្ចារ្យអ្វីម៉្លេះលោក ! ស្រាប់តែ ឆាំង !.. ឆាំង ! គ្រាំង ! គ្រាំង !.. ភ្លើងលាយផ្សែងបែកពេញផ្ទៃមាត់ទន្លេ ប្រៀបបាន នឹងរន្ទះរាប់ពាន់ រាប់ម៉ឺនបាញ់ផ្ទប់គ្នា ។ ស្នូរគ្រាប់ផ្ទុះមិនដឹងជាប៉ុន្មានដ កាត់ព្រៃ ភូមិបណ្ដោយមាត់ទន្លេ ឃើញតែអណ្ដាតអគ្គីនិងផ្សែងខ្មៅខ្មួ ផុះឡើង ដូចជាផែនដីឆេះផ្ទុះភ្នំភ្លើងអញ្ចឹង ។ គេមិនអាចដឹងបានថា ព្រឹត្តិការណ៍ដែលកើតឡើងប៉ុន្មាននាទីនោះ វាធ្វើឱ្យអ្វីៗ ទៅជាយ៉ាងណាទៅហើយ ?

គ្មានអ្នកណាដឹងទេ ស្រាប់តែថ្ងៃរះពេញពន្លឺ នាងសម្ផស្សដឹងស្មារតីឡើង ។ ខ្លួននាងទន់ដូចជាសំឡី ។ នាងខំបោសលំអងធូលីចេញពីខ្លួន ហើយខំបើកភ្នែកមើលទិដ្ឋភាពនៅជុំវិញខ្លួន នាងរវែករភ្នែកមើលបូរិន្ទ ប៉ុន្តែអ្វីៗ នៅទីនោះ ត្រូវប្រែប្រួលខុសពីសភាពដើមអស់រលីង ។ មុននេះប៉ុន្មាននាទី ធម្មជាតិទាំងឡាយមានសោភ័ណភាពស្រស់បំព្រង ឥឡូវប្រែទៅជាពណ៌ខ្មៅពភ្លាក់ ប្រឡាក់ដោយកំទេចដីលាយផ្សែងរសែវស្រមោកស្របក ។ សម្ផស្សខំប្រមូលកម្លាំងត្រដរក្រោកឡើង បោះជំហានទៅមុខបន្តិចឃើញរណ្ដៅគ្រាប់បែកមួយធំប៉ុនស្រះ ។ នៅជុំវិញរណ្ដៅនោះ មានគំនរដីឡើងបំនូកដូចជាអាចម៍ដីដែលគេទើបនឹងជីកលើកមកដាក់ថ្មីៗ ។ ក្រៅពីនោះដើមឈើនានាក៏ត្រូវអំបែងគ្រាប់រះផ្ដាច់បែកស្លួញស្លាញផ្លូល ព្រវេងច្រងាងប្រគាកប្រាគង



និងខ្ទាត់រប៉ាត់រប៉ាយ ។ សម្ផស្សចាប់នឹកឃើញថា បូរិន្ទបានរត់ទៅ បនៅកន្លែងមួយខាងមុខនាង ប្រហែលមិនឆ្ងាយប៉ុន្មានពីរណ្ដៅ គ្រាប់បែកនោះ តើអាយុជីវិតបូរិន្ទនឹងទៅជាយ៉ាងម៉េចទៅហើយ? នាង វែកស្មៅ ព្រែងទៅមុខរកមើលបូរិន្ទ :

" បងបូរិន្ទ ... បងបូរិន្ទអើយ ! បងនៅទីណា ? ... "

គ្មានសំឡេងបូរិន្ទឆ្លើយតបមកនាងវិញសោះ ! ប្រហែលជាសំ-ឡេងនាងស្រែកនេះមិនចេញសូរស័ព្ទក៏មិនដឹង ព្រោះពេលនោះត្រចៀកនាងរឹងស៊ិងទាំងអស់ ។ សម្ផស្សបោះជំហានទាំងទោរទន់ទៅមុខដោយខំស្រែកហៅបូរិន្ទបណ្ដើរ ក្នុងទ្រូងរបស់នាងចាប់ក្ដុកក្ដួលអួលណែនជាទីបំផុត ។ លុះពិនិត្យរកបូរិន្ទមិនឃើញ នាងក៏រលំខ្លួនដួលផេក នៅជិតរណ្ដៅគ្រាប់បូម ហើយចាប់យំៗ ទាល់តែបាត់សំឡេង ... ។

- ព្រះអាទិត្យចោលកំដៅក្ដៅឧណ្ហៗ មកលើដើមព្រឹក្សាលតា ល្ងើនិងភូមិករទាំងឡាយ ដែលត្រូវឆេះរោលរាលទៅដោយភ្លើង គ្រាប់រំសេវរបស់ចក្រពត្តិអាមេរិក ។ ពេលថ្មើរនោះ តាមធម្មតាជីវិតសត្វនិករគ្រប់ប្រភេទកំពុងធ្វើសកម្មភាពស្វែងរកអាហារ ល្បៀងជីពជន្ម តែឥឡូវនេះគ្មានទេ សូម្បីតែមូស សុចឬក្អាតក៏គ្មានមួយផង បរិយាកាសស្ងប់ស្ងាត់សែនមហាស្ងាត់ ! ស្ងាត់ដូចជាព្រៃវាឡទទេ .

មិនដឹងជាម៉ោងប៉ុន្មាន តែថ្ងៃរណ្ដែតខ្ពស់ពាក់កណ្ដាលមេឃទៅហើយ ទើបនាងសម្ផស្សបានដឹងស្មារតីឡើង មើលលោកនេះទៀត ។

នាងអស់សង្ឃឹមបានជួបបូរិន្ទ ក៏ដាច់ចិត្តបោះជំហានដើរទៅរកភូមិអ្នកស្រុក ។

នៅក្នុងភូមិ ក៏ដូចជាមីវាល និងព្រៃចំការដែរ ដើមឈើនិងផលដំណាំផ្សេងៗត្រូវគ្រាប់បាក់បែកខ្ទេចខ្ទាំកំបុតច្រងច្រាង។ ផ្ទះសម្បែងនានាបាក់ទ្រោមធ្លាក់ដំបូលស្របាំបៗ ហើយកន្លែងខ្លះ ក៏ត្រូវឆេះខ្ទេចមានផ្សែងភ្លើងនៅហុយៗនៅឡើយ ។ សម្ផស្សកើតការស្រងាកស្រងល់ និងស្លុតរន្ធត់ឥតឧបមា នៅពេលដែលនាងឃើញមនុស្សត្រូវគ្រាប់ស្លាប់ស្ដឹងៗ ស្ថិតនៅឯណេះមួយឯណោះមួយ លាយឡំនឹងសត្វស្លាប់ពាសកន្លែង។នាងដើរកាត់ទៅរកផ្ទះដ៏កំសត់របស់នាង។ផ្ទះនោះក៏ត្រូវបើងបាត់ពីកន្លែង មានតែកំណាត់ឈើរាត់រាយប៉ុណ្ណោះ។ សម្ផស្សចាប់ទង្គិះខ្សឹកខ្សួលម្ដងទៀត ដោយនាងនឹកគិតទៅដល់ឪពុក មិនដឹងជាគាត់ត្រូវស្លាប់ ឬ ខាត់ខាយទៅដល់កន្លែងណា ។ នាងចេះតែដើរពិនិត្យតាមទីនានា កាលណាជួបសាកសពមនុស្សនាងខំសង្កេតមើល ប៉ុន្តែសាកសពទាំងនោះ ខ្លះត្រូវធ្លាយពោះ ខ្លះបាក់ដៃជើង ខ្លះទៀតត្រូវខ្ទេចបែកមុខមាត់ ហើយដោយឥទ្ធិពលនៃគ្រាប់រំសេវរោលរាល ឆេះខ្លោចគ្រប់សរីរាង្គ នាងពុំអាចកត់សំគាល់បានថាអ្នកណាជាអ្នកណាឡើយ ។

សម្ផស្សពុំអាចទ្រាំនៅបានតទៅទៀត នាងដើររើសបានឆ្នាំងចានមួយសំរាប់ អង្ករ និងប្រហុកផ្អកបន្តិចបន្តួចយកធ្វើជាស្បៀង ហើយក៏



ចាកចេញពីភូមិនោះទៅ ។ នាងចេះតែដើរៗ ទៅពុំទាន់មានកំណត់ទិសដៅថាត្រូវទៅកន្លែងណាឡើយ ។

មួយសន្ទុះក្រោយមក ដំណើររបស់នាងបានចូលទៅដល់ចំការពោតមួយ ។ ចំការនេះស្ថិតនៅមិនឆ្ងាយប៉ុន្មានពីមាត់ទន្លេ ។ សម្ផស្សក្រឡេកឃើញខ្ទមមួយស្ថិតនៅកណ្ដាលចំការ ក៏ដើរចូលទៅឈប់សំរាក ។ នាងអង្គុយសញ្ជប់សញ្ជឹងនឹកគិតថា ការបាត់ខ្លួនរបស់បូរិន្ទធ្វើឲ្យនាងនឹកមិនអស់ចិត្តសោះ បូរិន្ទនៅរស់វង្វេងបាត់ពីនាងឬបូរិន្ទស្លាប់ ? បើសិនជាបូរិន្ទស្លាប់ ក៏នាងត្រូវរកឲ្យអស់ចិត្ត កាលណាឃើញសាកសព នាងនឹងរៀបចំទុកដាក់ឲ្យបានសមរម្យ ទើបរកផ្លូវទៅមុខទៀត ។ កំពុងតែគិតបែបនេះ ស្រាប់តែមានសំឡេងមនុស្សថ្ងូរឡើងនៅមិនឆ្ងាយប៉ុន្មានពីខ្ទម ។

“ អ៊ុយ ! លោកអើយជួយខ្ញុំផង ! ”

សម្ផស្សស្ដាប់ឮច្បាស់ ខំវេភ្នែកមើលទៅក្នុងចំការពោត ។ នាងឮសំឡេងដង្ហោយហៅនោះម្ដងទៀត ក៏ដាច់ចិត្តដើររកមើល ។ នាងហាក់ដូចជាស្មុំស្មារតីលែងខ្លាចខ្មោចលិតខ្មោចលងអីទៀតហើយ ។ ដើរទៅចំកន្លែងឮសូរប្រហែលជាងដប់ម៉ែត្រ សម្ផស្សប្រទះឃើញបុរសម្នាក់ស្ថិតនៅក្នុងវ័យប្រមាណជិតសែសិបឆ្នាំ ដេកនៅក្បែរគូទដំបូកមួយ ដែលមានមុខស្លេកស្លាំងជាទីបំផុត នាងឃើញសុទ្ធតែឈាមប្រឡាក់ខោ

និងអាររកមើលមិនយល់ ។ កាលឃើញសម្ផស្ស បុរសនោះក៏លើកដៃម្ខាងឡើង ដូចជាសំពះនាង :

ឱ ! នាងអើយ នាងមានអាយុថ្លៃថ្លាណាស់ ! សូមជួយខ្ញុំផង !

សម្ផស្សសង្កេតមើលយល់ថាបុរសនេះប្រហែលជាបាក់ជើង - បាក់ដៃ បានជាក្រោកមិនរួចហើយលើកតែដៃម្ខាង ។

- ចាស ពួកឯងយ៉ាងម៉េច បានជាមកដេកដួលនៅទីនេះ ?

- បាទនាង ខ្ញុំត្រូវរបួសបាក់ភ្លៅ និងបាក់ដៃម្ខាងខ្ទេច...

- ហ៊ឺ... ពួកជាប្រជាជននៅភូមិណា ?

- ឱ ! សូមជំរាបនាងតាមត្រង់ចុះ ខ្ញុំមិនមែនជាប្រជាជនទេ ៖

- ហ៎ា.. ពួកឯងជាអ្វី ?

- ខ្ញុំ ជាទាហានរដ្ឋការ

- ទាហានរដ្ឋការ ! ( សម្ផស្សឧទានសួនពាក្យនេះឡើងទៅឈរស្ងៀម ហើយមិនដឹងជាយ៉ាងម៉េចស្រាប់តែនាងខាំបបូរមាត់ខ្លួនឯងស្ទើរជាច់ចេញឈាម ) ។

មែនពាក្យមួយម៉ាត់នេះធ្វើឱ្យនាងនឹកឃើញភ្លាម ... ។ សេចក្តីឈឺចាប់ដែលកប់នៅក្នុងបេះដូងយូរមកហើយ ដោយសារតែអំពើព្រៃផ្សៃរបស់ទាហានរដ្ឋការ បានផុសកញ្ជ្រោលឡើង ធ្វើឱ្យនាងកើតហឹង្សាមួយរំពេច ។ នាងគិតថានឹងសម្លាប់អាទាហានរដ្ឋការនេះ ដើម្បីជាការសងសឹកដល់ជម្ងឺចិត្តរបស់នាង ។ សម្ផស្សក្រឡេកទៅជិតនោះឃើញអំបែង



គាប់បេមួយបន្ទះប្រវែងផ្ទៃកាំបិតដែលមានមុខរាបែកមុតល្អៀង នាងក៏ាកទៅ ចាប់រើសអំបែងនោះឡើងប្រុងសំពងបំបែកក្បាលអាទាហានរដ្ឋារម្នាក់នេះ ឱ្យស្លាប់តែហោងតែម្តង ។

" ឱ ! នាងអើយ ! សូមមេត្តាខ្ញុំផង ខ្ញុំត្រូវរបួសធ្ងន់ណាស់ សូមុំសម្លាប់ខ្ញុំថែមទៀត !... "

អាការៈភ័យញ័រទទាក់ និងសម្តីដ៏សោកសៅរបស់ជនរងគ្រោះនោះធ្វើឱ្យសម្ផស្សគាំងដៃនៅធ្មឹងដូចជារូបចម្លាក់។បន្តិចក៏របេះអំបែងនោះធ្លាក់ល់ដីនាងបែរមុខចេញស្រក់ទឹកភ្នែកច្រោកៗ!គឺជាទឹកភ្នែកក្តៅគគុកដែលកើតមកពីកំហឹងឈឺចាប់ តែពុំអាចធ្វើការសងសឹកទៅកើត ។ ពិតមែនហើយនាងខឹងចំពោះចក្រពត្តិអាមេរិក ពួករដ្ឋការហ្វាស៊ី ស! ប៉ុន្តែបើបែរសម្លាប់ជនរងគ្រោះស្រាប់ម្នាក់នេះ ក៏ដូចជាគ្មានប្រយោជន៍មិនខុសពីវាយខ្មោចងាប់ស្រាប់ទេ ។ម្យ៉ាងទៀត មេត្តាករុណាធម៌ដែលស្ថិតនៅក្នុងក្រអៅបេះដូងរបស់នាងជានារីខ្មែរនោះ បានលេចចេញមកជាការពិចារណា ធ្វើឱ្យនាងនឹកព្រួច ឃើញដល់ជីវិតខ្មែរ ឈាមខ្មែរ ...ានិច្ច ។

- ពួកឯង និយាយប្រាប់ខ្ញុំមើល៍ ហេតុយ៉ាងណាបានជាត្រូវរបួសមកសម្ងំនៅទីនេះ ?

- បាទនាង កាលពីយប់មិញនេះ ពួកខ្ញុំទាហានរដ្ឋការ បានប្រយុទ្ធនឹងកងទ័ពរណសិរ្ស ... ពួកខ្ញុំបាក់ទ័ពរត់ចោលសមរភូមិ ឯខ្ញុំ

របស់ដែក៏រត់មកពួនក្នុងចំការពោតនេះ ! ចង្រៃទៀបភ្លឺក៏មានយន្តហោះបេ៥២ មកចាក់គ្រាប់ខ្ញុំបាក់ភ្លៅទៀត ។

– ពូ ! ក្រែងយន្តហោះបេ៥២នោះជាគ្រឿងចម្បាំងការពារពូឯង ?

– បាទនាង វាជារបស់អាមេរិកទេ ! និយាយអញ្ចឹងខ្ញុំខ្លាចវាណាស់ !

– ហ៊ាក ! ចក្រពត្តិអាមេរិកជាចោរហ្វាយពូឯង ! ធ្វើជាបរិវារអាមេរិកម៉េចក៏ខ្លាចអាមេរិក ! ហើយម៉េចក៏មិនហៅអាមេរិកមកជួយ ?

ជនរងគ្រោះមិនហ៊ាននិយាយតទៀត បានត្រឹមយកដៃជូតទឹកភ្នែកចាប់យំគគេក !... ។ សម្ពស្សបោះជំហានដើរចេញ ជននោះក៏លើកដៃឡើងម្តងទៀត :

– ន នាងអើយ ! អាណិតជួយខ្ញុំយកបុណ្យទៅចុះ ! ខ្ញុំស្រេកទឹកណាស់ ! ឱ្យខ្ញុំសុំទឹកផឹកបន្តិចមក ។

សម្ពស្សងាកទៅស្រដី :

– ទ្រាំទៅ ! បើចង់រស់កុំរកទឹកផឹក !

នាងដើរមកកាន់ខ្ទមវិញ ហើយក៏អង្គុយសញ្ជប់សញ្ជឹងគិតសព្វគិតគ្រប់. .ក៏ប៉ុន្តែគិតយ៉ាងណាក៏ដូចជាមិនមានការធូរទូលាយចិត្ត មានតែដង្ហើមធំធ្លាយមកក្តៅគគុក។លុះពេលថ្ងៃត្រង់ជាក់ នាងចេញដើរទៅមាត់កំពុង ! រកដងទឹកមកដាំបាយហូប ។ ទៅដល់កន្លែងដែលបុរិន្ទនិងនាង



ព្រាត់គ្នា សម្ពស្សក៏ឈរទ្រឹងសម្លឹងមើលសព្វទិសទី ហើយវាត់ខ្សែភ្នែកទៅក្នុងផ្ទៃទន្លេ ឃើញទឹកហូរគ្រៀវៗ ចុះទៅ នាងក៏កើតការស្រងេះស្រងោចខ្លោចចិត្តរកទីបំផុតគ្មាន ។ នាងឈរត្រង់ខ្លួនភ្លឹងហ្នឹងថ្កល់យកដៃទាំងពីរក្តោបទ្រូង បីដូចជានាងប្រណម្យសុំឱ្យវត្ថុស័ក្តិសិទ្ធិក្នុងលោកនេះជួយឱ្យផុតពីសេចក្តីទុក្ខ ឬ បីដូចជារូបនាងទេពធិតាប្រុងហោះទៅកាន់ឋាននាយ ។

" ឱ! បងបុរិន្ទអើយ ! អូនមានទុក្ខអ្វីធំយ៉ាងនេះ បងទៅដល់ទីណាសូមនាំអូនទៅផង ដើម្បីឱ្យផុតពីសេចក្តីទុក្ខនៅក្នុងលោកនេះ ! ... "

ទឹកភ្នែកមិនដឹងមកពីណា ស្រាប់តែហូរស្រោចស្រពជោកវង់ភក្ត្ររបស់នាង នាងយំៗ ទាល់តែឆ្អែត ទើបដួសទឹកយកមកកន្លែងវិញ ។ សម្ពស្សដាក់ដាំបាយនិងអាំងផ្អកត្រីពីរ បីកន្ទុយ។ លុះឆ្អិនសព្វគ្រប់ហើយនាងក៏ដួសហូប ប៉ុន្តែទើបនឹងបានមួយម៉ាត់ ពីរប៉ុណ្ណោះ ក៏មានដុំមូលៗរត់ឡើងមកស្ទះបំពង់កនាងទៀត ។

ខណៈនោះ នាងឮសំឡេងជនរងគ្រោះថ្ងូរឡើងយ៉ាងអាណោចអាធម៍ ។ នាងដាច់ចិត្តយកបាយនិងម្ហូបទាំងអស់ទៅឱ្យជននោះ ។ គ្រាន់តែឃើញបាយនិងទឹក គេលើកដៃឡើងញ័រទទ្រើត មិនខុសអីពីមនុស្សដាច់ពោះចំណីអាហារ ឬ មនុស្សស្លឹឃាមហៅរកឱ្យគេជួយទេ។ គេទាញត្រឡោកទឹកពីដៃសម្ពស្សយកទៅផឹកយ៉ាងបង្ហំ ។ ប៉ុន្តែទើបបានលេបបី បួន ក្អឹក សម្ពស្សក៏កញ្ឆក់មកវិញ :

" យី ! ពួឯងដូចជារហន់ពេកហើយ ! ខ្ញុំបាននិយាយប្រាប់ហើយថា បើពួឯងចង់រស់កុំផឹកទឹក !.. ដឹងទេត្រូវរបួសអញ្ចឹងផឹកទឹកច្រើនមុខជាគ្រោះថ្នាក់ ! "

ចង់សម្ពស្សស្តីយ៉ាងម៉េចក៏បុរសនោះមិនហ៊ានតប គ្រាន់តែធ្វើភ្នែកភ្លឹះ ៗ .. ហាក់ដូចជាសុំអង្វរចិត្តនាងនិងសុំសេចក្ដីសន្ដោស ។

" ទេ ! ពួហូបបាយទៅ !..ហើយផឹកទឹកតែបន្តិចបានហើយ "

សម្ពស្សប្រើសម្ដីចំពោះជននេះ មិនបានផាក្ការសមគួរប៉ុន្មានទេ តែចិត្តនាងក៏មិនកាត់ផ្ដាច់ការអាសូរដែរ ។ នាងឃើញគេស្ថិតនៅកណ្ដាលថ្ងៃក្ដៅបែកញើសរហាមក៏មានចិត្តមួយឈឺឆ្អាល ដើរទៅរោចឈើពីរបងចំការយកមកធ្វើផាឃ្នះ រួចបោចដើមពោតប្រក់ពីលើខ្សែថែមទៀត ។

សម្ពស្សវិលមកកន្លែងគិតទោតទៀតថា នាងសំរេចចិត្តស្នាក់នៅកន្លែងខ្ទមនេះចំនួនពីរថ្ងៃ ពីរយប់ ដើម្បីស្រាវជ្រាវរកខ្មោចបូរិន្ទ ។ ថ្ងៃនោះនិងព្រឹកថ្ងៃបន្ទាប់នាងបានទៅមាត់ទន្លេ ខំកាយដីកន្លែងគ្រាប់បែចាក់ ក្រែងឃើញសាកសពបូរិន្ទ ប៉ុន្តែឥតអំពើសោះនាងរកយ៉ាងណាក៏មិនបានជួបប្រទះឡើយ ។

នៅវេលារសៀលត្រជាក់ សម្ពស្សវិលពីមាត់ទន្លេវិញ ក៏ធៀត ទៅមើលទាហានរដ្ឋការរងគ្រោះ ។ តែគួរឲ្យស្ដុតរន្ធត់ណាស់ !



នាងចូលទៅដល់ស្រាប់តែឃើញទាហាននោះ ដេកស្តូកស្តឹងរឹងក្រញង់ ភ្នែកបើកក្រឡោត មាត់ច្រហក្លង ហើយមានសត្វរុយរោមជុំជិត... ។

" អ៊ំា ! ពុទ្ធោ !... "

សម្ពស្សឧទ្ទានព្រមទាំងយកដៃខ្ទប់មុខ ងាកដើរចេញយ៉ាងស្រវាន់ ។

*

* *

# ៧

## រស់ក្នុងអន្លង់ទុក្ខ

ព្រះអាទិត្យកំពុងធ្វើដំណើរចូលទៅកាន់ទីអស្តង្គត ។ នាងសម្ផស្សបោះជំហានចេញពីខ្ទមចំការ មកអង្គុយត្រមោចត្រមង់ម្នាក់ឯងនៅមាត់ទន្លេ ។ នាងសែនខ្វល់ខ្វាយចិត្ត មិនដឹងគិតរកមធ្យោបាយណា នាំខ្លួនចេញផុតពីទីវេហារឋាន ។

គាប់ជួនបន្តិចក្រោយមក មានប្រជាជនមួយគ្រួសារ កំពុងធ្វើដំណើរដោយទូកតាមបណ្តោយទន្លេមេកុងចុះទៅក្រោម ។ សម្ផស្សដាច់ចិត្តស្រែកហៅអ្នកទូកនោះ គេក៏មានចិត្តធម៌ចូលមករកនាងមួយរំពេច ។ ក្រោយពីការសួរនាំ បានដឹងថាគេធ្វើដំណើរចេញទៅទន្លេតូច នាងក៏សុំដោយសារទូកនោះទៅ ។

ប្រហែលម៉ោងប្រាំបីយប់ ទើបអ្នកទូកនេះបានធ្វើដំណើរទៅដល់ភូមិព្រែកជ្រៃ ដែលស្ថិតនៅលើមាត់ច្រាំងដងទន្លេតូច ។ អ្នកម្ចាស់ទូកបានជូននាងសម្ផស្សទៅដល់ផ្ទះប្រធានភូមិ ។ ប្រធានភូមិនេះក៏បានទទួលនាងដោយរាក់ទាក់ ។ នៅពេលនោះ នាងសម្ផស្សបានសួររកឈ្មោះតា " ជ័យ " មួយរំពេច ។ កាលឮយុវតីបន្លឺរកឈ្មោះតាជ័យ សមមិត្តប្រធានភូមិកាន់តែមានការចាប់អារម្មណ៍ហើយនិយាយប្រាប់ត្រង់



តាជ័យជាបងបង្កើតរបស់គាត់ ។ សម្ផស្សត្រេកអរនិងកាន់តែមាន ក់ក្តៅ សំណូមពរឲ្យគាត់ជូនទៅផ្ទះតាជ័យតែម្តង ។

ពេលនោះ តាជ័យទើបនឹងសម្រាន្តតែពុំទាន់លក់នៅ ។ គាត់ក្រោក ទទួលយុវតីទាំងការងឿងឆ្ងល់ ព្រោះគាត់ពុំដែលស្គាល់នាងសម្ផស្ស ះ ។ សម្ផស្សលើកដៃសំពះតាចាស់ព្រឹទ្ធាចារ្យ ហើយចាប់និយាយ រាប់ពីរដំណើររបស់ខ្លួន ចុងក្រោយនាងក៏ដកកូនសំបុត្ររបស់អ៊ំស្ងួន ពីបង្វេច ហុចជូនទៅគាត់ ។

តាជ័យ និងប្រធានភូមិ បានដឹងរឿងហេតុសព្វគ្រប់ កើតការស្រ ចិត្តនឹកអាណិតនាងក្រៃលែង ។ តាជ័យពោលឡើងទាំងទឹកមុខ ស្ងួត :

- ក្មួយស្រី អ៊ំស្តាយណាស់ រឿងស្ងួនមិត្តភ័ក្តិរបស់អ៊ំបានបញ្ជូន ប្រុស ក្មួយស្រីមកអ៊ំហើយ បែជាត្រូវទទួលគ្រោះថ្នាក់បែកបាក់គ្នា ជាសេចក្តីទុក្ខព្រួយមួយដ៏ធំ អ៊ំនឹងជូនដំណឹងទៅស្ងួនវិញ ពីការបាត់ ក្មួយបុរិន្ទ ឯក្មួយនៅជាមួយអ៊ំនេះហើយ ។

- ចាស ! ( សម្ផស្សបន្លឺវាចាក្នុងភាពស្រពាប់ស្រពោនចិត្ត ) លនេះនៅសល់តែខ្ញុំម្នាក់គត់ ប្រៀបដូចជាបក្សីព្រាត់គូ ហើយគ្មានទី ងទេសូមអ៊ំមេត្តាជួយសន្តោសប្រណីដល់ជីវិតខ្ញុំផង ។

- ពេញ្ញាយស្ងប់ចិត្តទៅចុះក្មួយណ៎ា ធ្វើម៉េចប្រទេសជាតិមាន ង្គ្រាម តែងតែមានការព្រាត់ប្រាសនិរាស . . ស្ងួនអ៊ំក៏ត្រូវបាត់បង់

កូនចៅអស់មួយចំនួនដែរ ។ និយាយអញ្ចឹង ក្មួយប្រាប់ពីសារ
ម្តាយក្មួយឱ្យអ៊ំបានដឹងផងមើល៍ ?

– ចាស ឪពុករបស់ខ្ញុំឈ្មោះ ភួន នៅភូមិកោះកែវ . .

– ហ៎ាក ! (ប្រធានភូមិឧទានកាត់ឡើង) នាងជាកូនរបស់
នៅភូមិកោះកែវនេះទេ ?

– ចាស !

– អញ្ចឹង បានជាខ្ញុំ ដូចប្រហាក់ប្រហែលមុខ

– ចាសពីមុនខ្ញុំធ្លាប់ដើររកស៊ីជាមួយឪពុកខ្ញុំ មកភូមិ
លោកពូបានស្គាល់ឪពុករបស់ខ្ញុំច្បាស់ឬ ?

– ពូស្គាល់ច្បាស់ណាស់ ! ( ប្រធានភូមិបញ្ជាក់ប្រាប់ )
ជាប្រជាជនចំរើនជឿនលឿនមួយរូប គាត់មានទំនាក់ទំនងនឹងអ្នក
នៅភូមិយើង ហើយបានចូលរួមចំណែកក្នុងការធ្វើសង្គ្រាមរំដោ
តាំងពីរណសិរ្សកកើតឡើងម្ល៉េះ ប៉ុន្តែគាត់ត្រូវខ្មាំងចាប់ខ្លួនបាននៅ
បញ្ជូនទ័ពទៅស្រុកលើកដែក . . .

– ចាស គឺពិតជាឪពុករបស់ខ្ញុំណ៎ាពូ ឥឡូវនេះគាត់ស្លាប់
នៅទីណាពូដឹងទេ ព្រោះខ្ញុំបែកពីគាត់ច្រើនខែហើយ !

– មែនហើយ ! ( តាជ័យពោលទៅកាន់ប្អូនគាត់ជាប្រធា
អន្ទិតជុំឯងបានដឹងរឿងភួនច្បាស់ ឥឡូវភួននេះត្រូវជាឪពុកក្មួយស
ឯងនិយាយប្រាប់ក្មួយឱ្យបានដឹងសព្វគ្រប់ផងទៅ !



ធានភូមិចាប់បរិយាយប្រាប់នាងសម្ផស្ស :
ក្មួយស្រី . . . ពេលដែលពួកទាហានរដ្ឋការបានដោះលែង
ប់ក្មួយមកផ្ទះវិញ គាត់ត្រូវធ្លាក់ខ្លួនឈឺគ្រាំគ្រាដោយសារតែការ
កម្មរបស់ពួកវា ។ គាត់គ្មានបានរកស៊ីអ្វីទេ មានតែការលក់
បរនៅក្នុងផ្ទះយកលុយកាត់មើលជម្ងឺខ្លួន ។ ចាប់ពីពេលនោះមក
ណ៍នៅភូមិកោះកែវ មានសភាពធ្ងន់ធ្ងរជាលំដាប់ កន្លែងនោះ
បន់ប្រទង់ប្រទាញរវាងកងទ័ពរណសិរ្ស និងទាហានរដ្ឋការ
យមានការប្រយុទ្ធគ្នាជាញឹកញាប់ ។ ប្រជាជនទ្រាំរស់នៅមិន
ដកខ្លួនថយមកស្នាក់នៅតាមភូមិនានាក្នុងតំបន់រំដោះ ប៉ុន្តែនៅទី
មានបុរសចាស់ ៗ ខ្លះនៅចាំផ្ទះសម្បែង និង ការពារទ្រព្យ
សត្វពាហនៈ ។ បងភួនដែលមានជម្ងឺ ត្រូវបានបងប្អូនប្រជាជន
ខាង ដឹកយកមកនៅភូមិព្រែកជ្រៃនេះ។ ពូជាប្រធានភូមិនៅទីនេះ
ទួលគាត់ ហើយរកកន្លែងឱ្យស្នាក់អាស្រ័យបានសមគួរ ។ ប៉ុន្តែ
កន្លងមកនេះ មានបងប្រុសរបស់គាត់ម្នាក់ឈ្មោះភិន នៅព្រែ
ស្រុកមេសាងបានមកសុំយកគាត់ទៅព្យាបាលជម្ងឺ និង ចិញ្ចឹមថែ
នៅទីនោះ ។ ពូក៏បានឯកភាពឱ្យគាត់ទៅ ហើយបានទទួល
ដំណឹងមកថា សព្វថ្ងៃគាត់នៅរស់ទេក្មួយ ។

សម្ផស្សបានទទួលដំណឹងពេលនេះ ថាឪពុកនៅរស់នាងត្រេកអរ
ប្រៀបពុំបាន។ នាងសូមថ្លែងអំណរគុណចំពោះប្រធានភូមិដែលបាន

យកចិត្តទុកដាក់ជួយជ្រោមជ្រែងគាំពារជីវិតឪពុករបស់នាង ។ នាង
ថា ត្រូវស្នាក់អាស្រ័យនៅភូមិព្រៃក្រែវនេះមួយរយៈរង់ចាំថ្ងៃណាមួ
មានឱកាសល្អ នាងនឹងនិយាយសុំតាជ័យ និងពូជុំប្រធានភូមិ ទៅ
ទៅតាមរស់នៅជាមួយឪពុក នៅស្រុកមេសាងនោះវិញ ។

*

* *

នាងសម្ផស្សស្នាក់នៅក្នុងភូមិព្រៃក្រែវបានតែពីរសប្តាហ៍ប៉ុណ្ណ
ក៏សុំលាតាជ័យចេញទៅរកឪពុក ។ តាជ័យបានឱ្យពូជុំជាប្អូនជូនធា
រហូតទៅដល់ភូមិព្រៃឃ្មុស ស្រុកមេសាង ។ នាងក៏បានជួបឪពុកនិ
ធំភិនដូចបំណង ។

ធំភិននិងពូភិន ជាបងប្អូនបង្កើតនឹងគ្នា ។ គាត់មានគ្រួសារ ស៊ុ
នៅឆ្ងាយពីគ្នាយូរហើយ ។ ក្នុងប៉ុន្មានឆ្នាំកន្លងមក ដោយសារសង្គ្រា
គាត់ផ្តាច់ផ្លូវគមនាគមន៍ គ្រួសារទាំងពីរពុំដែលបានទាក់ទងដឹងសុខទុ
គ្នាទេ ។ ទើបតែឆ្នាំនេះ ដែលពូភិនមានគ្រោះថ្នាក់ធ្លាក់ខ្ទមឈើ ហើ
បានខ្ចាត់ខ្ចាយមកដល់ភូមិព្រៃក្រែវ ធំភិនបានដឹងដំណឹងក៏ទៅទទួលយ
មកថែរក្សា។ ធំភិនក៏ជាបុរសពោះម៉ាយដូចពូភិនដែរ ប្រពន្ធគាត់ទើបនឹ
ទទួលអនិច្ចកម្មដោយជំងឺក្នុងរវាងមួយឆ្នាំ ។ គាត់មានកូនពីរនាក់ដែល
មានវ័យតិចជាងនាងសម្ផស្សទៅទៀត ។ កូនប្រុសរបស់គាត់ឈ្មោ
សុភាអាយុ ១៦ ឆ្នាំ និងកូនស្រីឈ្មោះ នាងភារីអាយុទើបបាន១៣ឆ្នាំ



កាលនាងសម្ផស្សធ្វើដំណើរទៅដល់ អ្នកទាំងអស់ក្នុងគ្រួសារ
នេះភ្ញាក់ស្មារតីគ្រប់ៗគ្នា ដោយមិននឹកស្មានថា សម្ផស្សមានភ័ព្វវាស
នាបានមកជួបជុំពួកគេឡើយ ។ ពិសេសពូភិនជាឪពុកមានចិត្តរំភើប
ជាងគេ ។

ពូភិនក៏អញ្ចឹងដែរ កាលឃើញសម្ផស្សចូលទៅជិត គាត់ខំលើកដៃ
រញីរញ័រអង្អែលកូន ហាក់ដូចជាគាត់សប្បាយចិត្តពេកណាស់ តែការ
សប្បាយនោះទៅជាកំសួលអួលណែនពេញដើមទ្រូង បណ្តាលឱ្យហៀរ
ទឹកភ្នែកពព្រិចទៅវិញ ។

បរិយាកាសបែបនោះ ទោះបីឃើញខំពណ៌នាអំពីសេចក្តីទុក្ខសោក
លាយឡំនឹងការនឹករលឹករបស់អ្នកទាំងពីរ ក៏មិនអស់សេចក្តីពិស្តារដែរ ។
ពេលនោះធំភិននិងកូនរបស់គាត់ទាំងពីរក៏ចូលមកជួបជុំគ្នា ។ គ្រួសារ
ធំភិន និង នាងសម្ផស្សក៏ចាប់ប្រាស្រ័យសាកសួរសុខទុក្ខគ្នាទៅវិញទៅ
មកអស់រយៈកាលជិតប្រាំនាទី ។ ចុងក្រោយ ធំភិនក៏សាកសួរនាង
សម្ផស្ស ឱ្យតំណាលពីរឿងរបស់នាងឡើង ។

នៅពេលដែល នាងសម្ផស្សបានរៀបរាប់ប្រាប់សព្វគ្រប់ពីដំណើរ
ជីវិតរបស់នាង អ្នកទាំងអស់កើតការតក់ស្លុតរន្ធត់ចិត្តឥតឧបមា ហើយ
អាណិតអាសូរនាងគ្រប់ៗគ្នា ។ ពូភិនយកក្រមាជូតទឹកភ្នែកដាញឹក
ញាប់ គាត់ខំពោលឡើងទាំងសំឡេងញ័រតិចតុប :

– សម្ផស្សកូន រឿងកូនអភ័ព្វណាស់ ! ...ហ៊ឺ...ពេលនេះអ្វីៗដែលជាទីស្រឡាញ់នៃយើងត្រូវព្រាត់ប្រាសនិរាសអស់ហើយ ! ឪពុកតែងគិតថាក្នុងជីវិតរស់នៅនៃមនុស្សលោក មានតែរូបឪពុកទេដែលរងទុក្ខខ្លោចផ្សាជាងគេ ឥឡូវកូនបានឆ្លងកាត់សង្គមនេះ ក៏ជួបប្រទះនូវមហាទុក្ខសោកវេទនាហួសឪពុកទៅទៀត ! កូនព្រាត់ពីឪពុកត្រូវពួករដ្ឋការហ្វាស៊ីសយកទៅធ្វើបាប ត្រូវចក្រពត្តិអាមេរិកម្នាក់គ្រាប់បែករហូតដល់ព្រាត់ប្រាសនិរាសប្តីជាទីស្រឡាញ់ ...

–ណ្ហើយកូន. . . ធំភិនដែលជាចាស់ព្រឹទ្ធាចារ្យចេះដឹងជ្រៅជ្រះពោលឃាត់ពួកកូនកុំឱ្យយំសោក រឿងនេះ មិនមែនជាអកុសលកម្មឬការផ្តន្ទានៃព្រហ្មលិខិតចំពោះយើងទេ គឺជាផលវិបាកនៃសង្គ្រាម ! សង្គ្រាមបណ្តាលឱ្យវិនាសហិនហោច បាត់បង់ទឹកដីអាយុជីវិតប្រជាជន ទ្រព្យសម្បត្តិនិងវត្ថុមានតម្លៃរបស់ប្រទេសជាតិ ។ ក្នុងប្រវត្តិការណ៍អតីតកាលកន្លងមករាប់ពាន់ឆ្នាំ រជ្ជកាលស្តេចណាក៏មានសង្គ្រាមដែរ រហូតមកទល់បច្ចុប្បន្ននេះរឿយៗក៏នៅតែជួបប្រទះសង្គ្រាម !

– មែនហើយបង ពូភូនខំពោលតប តាំងពីក្មេងមកទល់ពេលនេះខ្ញុំមានអាយុហាសិបប្អូនឆ្នាំហើយ ខ្ញុំបានឆ្លងកាត់ពីរ បីជំនាន់ ប៉ុន្តែខ្ញុំពុំដែលជួបប្រទះគ្រោះកាចចង្រៃណា ដែលសាហាវស្មើសង្គ្រាមចក្រពត្តិអាមេរិកទេ ! . . . ចក្រពត្តិអាមេរិកជាមហាអំណាចឃោរឃៅជើរប្រល័យលោក! ការបាត់បង់ជីវិតនៃគ្រួសារខ្ញុំ ធ្វើឱ្យខ្ញុំឈឺចាប់ណាស់!



– អ្នកណាក៏ឈឺចាប់ដូចឯងដែរណាំភូន ការឈឺចាប់ទាំងនេះក្លាយទៅជាហឹង្សារបស់មហាជន ព្រោះប្រជាជនខ្មែរស្ទើរទាំងមូលងគ្រោះ អញ្ចឹងបានយើងហ៊ានលះបង់ចូលរួមក្នុងចលនាតស៊ូធ្វើង្គ្រាមប្រជាជន វាយចក្រពត្តិអាមេរិក និង ពពួកបរិវារវា ។ សព្ារតស៊ូរបស់ប្រជាជនយើងកាន់តែមានការរីកឡូន៍ទៅមុខ យើង:បានទឹកដីយ៉ាងធំទូលាយ ហើយនៅថ្ងៃអនាគតយើងច្បាស់ជា:បានប្រទេសជាតិទាំងស្រុង ។ ប្អូនភូនឯងជាអ្នកបានចូលរួមចំកតស៊ូដែរ ប៉ុន្តែឥឡូវនេះឯងធ្លាក់ខ្លួនឈឺបាត់បង់កម្លាំងពលកម្មយ ... ហ៊ាំ . . ប្រឹងប្រែងពង្រឹងស្មារតីទៅណាំ ក្រែងបានរស់ឃើញពន្លឺបដិវត្តន៍ ។

និយាយដល់ត្រង់ណេះ ធំភិនក៏ងាកមកអង្អែលក្បាលនាងសម្ផស្ស:

–ក្មួយស្រី ធំសប្បាយចិត្តណាស់ ការដែលក្មួយបានមកជួបជុំនឹងកព្រមទាំងបងប្អូនយើងឡើងវិញ ក្មួយខំមើលឪពុកទៅណាំ ជម្ងឺនេះទាន់អស់លទ្ធភាពព្យាបាលទេ ។

– ចាំសធំ ខ្ញុំនឹងយកអស់ពីកម្លាំងកាយ ចិត្ត មើលថែទាំពុក...។

ធំភិនញញឹម លើកដៃអង្អែលក្បាលក្មួយម្តងទៀត រួចក្រោកពីឃចេញទៅធ្វើកិច្ចការនៅខាងក្រៅផ្ទះ ទុកឱ្យក្មេងៗ នៅសំណេះណាលគ្នាតទៀត ។

*

* *

ពេលវេលាចេះតែកន្លងផុតទៅ ដោយនាំយកនូវសេចក្តីសុខ និងសេចក្តីទុក្ខនៃមនុស្សរាល់រូបទៅជាមួយផង ។ ប៉ុន្តែពេលវេលាថ្មីដែលមកដល់បច្ចុប្បន្ន និងទៅអនាគតក៏រមែងកើតមានសេចក្តីសុខ និងសេចក្តីទុក្ខឡើងវិញជាធម្មតា ។ ឆ្លងពីរដូវមួយទៅរដូវមួយ បរិយាកាសមានការប្រែប្រួលជានិច្ចកាល ធម្មជាតិនានាក៏មានការផ្លាស់ប្តូរសោភ័ណភាពទៅតាមពេលវេលានោះដែរ ។

ឈានមកដល់រដូវប្រាំង ឆ្នាំ ១៩៧៥ សង្គ្រាមប្រជាជនមានសន្ទុះខ្លាំងបំផុត ប្រៀបបីដូចព្យុះសង្ឃរា ឬ ទឹកជំនន់បាក់ទំនប់ ដែលគ្មានអានុភាពអ្វីអាចមកទប់ទល់បានឡើយ ។ ចក្រពត្តិមេក្លោងសង្គ្រាម មានទីប្រឹក្សា ទូតអាមេរិកចាប់ភ័យស្លន់ស្លោភ្នែកមូលដូចកាក់នាំគ្នារត់ឡើងយន្តហោះកន្ត្រប់ប្រសេចប្រសាច ។ ពួកអាយ៉ងលន់ នល់ សក្តិធំៗ ដុះពោះស្ពុយៗ ក៏នាំគ្នារេចសំពាយរត់តាមចៅហ្វាយនាយ ទាំងព្រលឹងនៅចុងសក់ ។

ថ្ងៃ ១៧ មេសា កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្ត វាយសម្រុកចូលរំដោះបានរដ្ឋធានីភ្នំពេញទាំងស្រុង ហើយក៏រំដោះបានបណ្តាខេត្តនានានៅទូទាំងប្រទេស ។ ប្រជាជនយើងទាំងមូល មានមោទនភាពក្រៃលែងចំពោះស្នាដៃនៃការតស៊ូរបស់ខ្លួន ដែលបានសំរេចផលនៅទីចុងបំផុតហើយក៏បាននាំគ្នាអបអរសាទរយ៉ាងក្លៀវក្លា ចំពោះថ្ងៃជ័យជំនះជាប្រវត្តិសាស្ត្រនេះ ។

- ប៉ុន្តែ គួរឲ្យសោកស្តាយជាទីបំផុត ពេលនោះស្រាប់តែសភាពការណ៍ប្រែក្រឡាប់ចក្រទៅវិញ ។ មេដឹកនាំខ្មែរក្រហម ឆ្លៀតយកឱកាសនោះ បានប្រើអំណាចផ្តាច់ការ ឆក់ប្លន់យកសមិទ្ធផលបដិវត្តរបស់ប្រជាជន ។ ហួសស៊ីសផុតលេខ វាបានបញ្ជាទាហានខោខ្មៅអាវខ្មៅដេញប្រជាជនចេញពីទីក្រុងទាំងអស់ ។ ម្នាក់ៗ ភ្ញាក់ខ្លួនស្រឡាំងកាំង ទឹកហូរសចិត្តឥតហ៊ានតវ៉ានឹងអាជ្ញាធររបស់គេ សុខចិត្តដឹកកូនជញ្ជូនចៅ ចេញចោលផ្ទះសម្បែងទាំងតូចចិត្ត ។ មិនយូរប៉ុន្មានអ្នកទាំងអស់នោះ ត្រូវគេជម្លៀសទៅដល់មូលដ្ឋានដ៏គគ្រឹកគគ្រេង ។

នៅមូលដ្ឋាន មេដឹកនាំខ្មែរក្រហមក៏ចាប់បញ្ជារដ្ឋអំណាចឲ្យធ្វើការប្រែប្រួលរបបឃុំគ្រងទៅតាមផែនការរបស់គេយ៉ាងឆាប់រហ័ស ។ ពេលនោះហើយទើបប្រជាជន ទូទាំងប្រទេសយល់ថាមានការកែប្រែសង្គមរស់នៅមួយយ៉ាងប្លែក ខុសអំពីផលប្រយោជន៍របស់ខ្លួន ។

អ្នកណាក៏ដឹងដែរថា កាលនៅក្នុងរយៈកាលតស៊ូប្រជាជាតិ អង្គការរណសិរ្សបានប្រមូលផ្តុំកម្លាំងប្រជាជនគ្រប់ស្រទាប់វណ្ណៈ ធ្វើសង្គ្រាមវាយចក្រពត្តិអាមេរិក និងពួកស្តាំនិយមលន់ នល់ ដើម្បីរំដោះជាតិ មាតុភូមិរួចហើយឈានទៅកសាងសង្គមមួយថ្មី គឺសង្គមនិយមប្រកាន់ខ្ជាប់នូវលទ្ធិម៉ាក្សលេនីនដ៏ល្អបរិសុទ្ធ ។ ប៉ុន្តែផ្ទុយស្រឡះ ពេលបានទទួលជ័យជំនះហើយ មេដឹកនាំខ្មែរក្រហម បានប្រែក្រឡាស់ផ្លាស់

ទិសដៅទៅជាបង្កើតឡើងនូវរបបមួយហៅរហៅហ្វាស៊ីស អារក ហុត ឃាមអង្កៀមឆ្អឹងប្រជាជនធ្ងន់លើសរបបមុនៗ ទៅទៀត ។ គេបាន ប្រសិទ្ធិនាមរបបថ្មីនោះថា " កម្ពុជាប្រជាធិបតេយ្យ "។ កម្ពុជាប្រជា-ធិបតេយ្យ គឺជាសង្គមនិយមក្លែងក្លាយដើរតាមលទ្ធិចិនម៉ៅ ។ ក្រោយ ឃីហោកុងម៉ាថា " កម្ពុជាប្រជាធិបតេយ្យអនុវត្តចលនាមហាលោត ផ្លោះ មហាអស្ចារ្យ "គេបញ្ជាដោយងងឹតងងល់ឱ្យរដ្ឋអំណាចចាត់តាំង ធ្វើសហករណ៍ភាវូបនីយ៍កម្មដោយទ្រង់ទ្រាយធំបំផុត ។ សហករណ៍ នោះគឺជាគុកឥតជញ្ជាំង ដែលឃុំឃាំងមនុស្សឱ្យរស់នៅក្នុងជីវភាព វរាងបាយរួមដ៏ស្មោគគ្រោក និងការលត់ដំធ្វើពលកម្មយ៉ាងធ្ងន់ធ្ងរបំផុត។

ក្នុងពេលគេកំពុងរៀបចំធ្វើសហករណ៍រួមនោះ ពូភួនធ្លាក់ខ្លួនឈឺ ធ្ងន់ ។ ទោះបីធំភន នាងសម្ផស្ស ខំរកគ្រូហ្មព្យាបាលយ៉ាងណា ក៏ខ្លួនគាត់គ្មានធូរស្បើយ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពូភួនចេះតែដុនដាប ទៅ ។ រហូតដល់គាត់រង់ចាំតែថ្ងៃអង្សាប៉ុណ្ណោះ ។ នាទីចុងក្រោយនៃ ការដឹងខ្លួនរបស់គាត់ ។ បានពោលផ្ដែផ្ដាំនាងសម្ផស្សថា :

- " សម្ផស្សកូន ឪពុកមិនបាននៅឃើញមុខកូនតទៅទៀតទេ. . សេចក្ដីសង្ឃឹមរបស់ឪពុកដែលថារង់ចាំទទួលពន្លឺបដិវត្តន៍នោះ ក៏ផុតរលត់ ត្រឹមនេះ. ឥឡូវប្រទេសបានរំដោះហើយ ប៉ុន្តែក្រោយពេលរំដោះគេ ឃើញសភាពការណ៍មានការវិវឌ្ឍន៍ប្លែកណាស់ ! ពុកយល់ថាការរៀប ចំសង្គមរបៀបនេះ មិនមែនជាសង្គមនិយមបរិសុទ្ធទេ!..ចូរកូនខំហាត់ពត់



លត់ដំឥរិយាបថសម្របសម្រួលខ្លួនរស់នៅ ហើយខំតស៊ូក្នុងជីវិតតទៅ ទៀតណា៎" ។

ពូភួនខំពោលបានប៉ុណ្ណោះក៏ចាប់ផង្គក់.. បន្ទាប់មកក៏បាត់មាត់បាត់ កលែងនិយាយស្ដីរួច មានតែខ្យល់ដែលធ្លាយចេញមកតាមមាត់យូរៗ ប៉ុណ្ណោះ។ ដោយការអស់សង្ឃឹម នាងសម្ផស្សប្រុះនៀលនៅជិតឪពុក យំសោកបោកខ្លួនដូចសត្វអក ។ ពេលនោះចាស់ទុំនៅជិតខាងក៏ឡើង អកជួបជុំគ្នានៅចាំកំដរ និងត្រៀមខ្លួនជួយយករអាសា ។ តាចាស់ស្រុក ម្នាក់មានប្រសាសន៍ទៅកាន់ធំភនដែលអង្គុយអបពូភួននោះថា ៖

= ហ៊ឹ ..ភិនអើយ .:ឥឡូវនេះ គេឱ្យយើងចូលសហករណ៍រួមទាំង អស់គ្នាហើយចាប់ពីពេលនេះទៅ ធ្វើការរួម ហូបរួម ហើយគេផ្ដាច់កម្ម សិទ្ធិអស់រលីង តាំងពីមនោសញ្ចេតនាគ្រួសារសាច់ញាតិជាដើម នៅ មានតែកម្មសិទ្ធិសមូហភាពមួយមុខប៉ុណ្ណោះ មើលទៅថ្ងៃមុខយើងមិន អាចជួយយកអាសាគ្នាបានទេ !...ណ្ហើយបើភួន វាលាចាកលោកក្នុង ពេលនេះទៅ ក៏ដូចជាអស់សេចក្ដីកង្វល់ដែរ នៅយើងក្រោយៗ មិនដឹង យ៉ាងណាទេ វីរដល់ពេលស្លាប់គ្មានគេកប់ ? ..ពេលនេះសំណាងភួន ហើយ !... ។

កាលតាចាស់និយាយដូច្នេះ នាងសម្ផស្សខំពង្រឹងស្មារតីឈប់យំ សោក ហើយនាងតាំងចិត្តស៊ូងស្ងាធដើម្បីជូនដំណើរឪពុកទៅកាន់

លោកខាងមុខឱ្យបានប្រកបទៅដោយនិរទុក្ខ ។ នៅពេលថ្ងៃរៀបលិចព្រួញក៏រលត់សង្ខារទៅ ។

*

* *

ដូចតាចាស់ស្រុកមានប្រសាសន៍ត្រូវមែន ចាប់ពីពេលនោះមកសហករណ៍សម្ពហភាពក៏កើតឡើងនៅគ្រប់ទីកន្លែង ។ ប្រជាជនទាំងអស់ ស្ថិតនៅក្រោមការគ្រប់គ្រងដ៏តឹងរ៉ឹងរបស់ប្រធានសហករណ៍មួយរូប ឬប្រធានកងតូច "១" និងប្រធានក្រុម ពួករបស់គេមួយចំនួនទៀត ។ គេបានបែងចែកកម្លាំងមនុស្សជាពីរ បីប្រភេទ ប្រភេទវ័យចាស់គេឱ្យធ្វើកិច្ចការបន្ទាប់បន្សំ ប្រភេទបុរស-ស្ត្រីវ័យកណ្ដាលដែលមានកម្លាំងពលកម្មពេញលេញគេចាត់តាំងឱ្យធ្វើការងារធ្ងន់និងសំខាន់ៗប្រចាំថ្ងៃ ឯយុវជន នារីនៅលីវ គេចាត់បញ្ជូនទៅនៅក្នុងកងចល័តទាំងអស់ ។

ពេលនេះ ធំភិនគ្មានសិទ្ធិធ្វើជាអាណាព្យាបាល លើកូនប្រុសស្រីនិងក្មួយរបស់គាត់ទៀតទេ ។ យុវជន សុភា កូនប្រុសរបស់គាត់ត្រូវអង្គការគេហៅឱ្យចូលទៅធ្វើការនៅមន្ទីរកសិកម្មស្រុក ។ ចំណែកនាងភារី និងនាងសម្ផស្ស ក៏ត្រូវកងធំគេយកទៅនៅប្រមូលផ្ដុំក្នុងកងចល័ត ។

របបនៅក្នុងកងចល័ត ក៏មិនខុសប្លែកពីរបបនៅកងតូចឬ សហករណ៍ភូមិប៉ុន្មានដែរគឺធ្វើការរួម ហូបចុករួម ជាយាខ្លះត្នោតសម្លប្រហុកដូចគ្នា ។

"១" - ក្នុងរបបកុម្មុយនិស្តប្រជាធិបតេយ្យ សហករណ៍រលិតកម្មនៅភូមិហៅថាកងតូច នៅឃុំហៅថាកងធំ ។



ប៉ុន្តែ ការស្នាក់នៅ គេប្រមូលផ្ដុំក្នុងជំរំសម្ពហភាពមួយដោយរៀបចំក្រុមយុវជនដោយឡែក ក្រុមនារីដោយឡែក ។ ការងារសំខាន់គឺគេប្រមូលផ្ដុំកម្លាំងកងចល័តនេះ លើកប្រព័ន្ធភ្លឺស្រែ ជីកប្រឡាយកាយដីលើកទំនប់ទប់ខាត់ខ្វែង ទៅតាមផែនការកែប្រែដីធ្លីរបស់អង្គការគេ ។ ជាបន្តបន្ទាប់មកកម្លាំងនេះត្រូវវាយសំរុកធ្វើស្រែវស្សា ប្រាំងទាំងយប់ថ្ងៃគ្មានឈប់ឈរ ដោយដាក់កំរិតធ្វើឱ្យបានពីបីតោន ទៅប្រាំមួយតោន ប្រាំពីរតោន . . . ក្នុងមួយហិកតា ។

សម្ផស្សរស់នៅក្នុងកងចល័តរហូតបានពីរឆ្នាំ ដោយខំស៊ូទ្រាំនឹងការលំបាកវេទនាគ្រប់បែបយ៉ាង។ ជីវិតដែលស្រោបទៅដោយបរិយាកាសសង្គមដ៏ខ្មៅងងឹត និងស្អុយអាសោច ឯាងសម្ផស្សក៏ដូចជាយុវជននារីឯទៀត គ្មានបានយល់ដឹងអ្វីពីលោកជុំវិញទេ ព្រោះគេបំបិទសិទ្ធិសេរីភាពអស់រលីង ។ ថ្ងៃណាក៏ជាថ្ងៃការងារ ថ្ងៃណាក៏បញ្ចេញកម្លាំងពលកម្មហូរញើសតាងទឹក បើកភ្នែកឡើងឃើញតែមនុស្សស្លៀកពាក់ខ្មៅចុះមីរដេរដាសក្នុងការដ្ឋានដូចហ្វូងក្អែក ។

ថ្ងៃមួយក្នុងរដូវប្រាំងដើមឆ្នាំ ១៩៧៧ អាទកម្មាភិបាលថ្នាក់ស្រុកម្នាក់ចុះមកត្រួតពិនិត្យការងារនៅក្នុងកងចល័ត។ពេលនោះកងចល័តកំពុងវាយសំរុកជីកព្រែកមួយដែលកាត់ពីស្រុកកំចាយមារមកស្រុកមេសាង ។

នាងសម្ផស្សទើបនឹងធ្វើពលកម្មបានបីថ្ងៃ ក៏ចាប់មានជម្ងឺគ្រុនក្ដៅ នាងបានសុំច្បាប់ប្រធានក្រុមនារី ឈប់សំរាកនៅក្នុងរោងស្នាក់អាស្រ័យ ។

នៅលើការដ្ឋាន គេសង្កេតឃើញ ជនដែលមានឋានៈជាអ្នកដឹកនាំរបស់ស្រុកនោះ កំពុងដើរត្រួតពិនិត្យពលករកាប់កាយដី ដោ[…] ឬក្រអឺតក្រទម ។ លុះថ្ងៃក្ដៅចង្អិច គេក៏ដើរមកពិនិត្យនៅតាមខ្ទ[…] របស់កងចល័តទៀត ។

សម្ផស្សកំពុងគ្រុនក្ដៅ ដេកដណ្ដប់ក្រមានៅលើរានមួយដែ[…] គ្រាលដោយរនាបឬស្សី ។ កាលឃើញជននោះដើរមកដល់ នា[…] ក្រោកឡើងអង្គុយភ្ញាក់ ។ នាងមានការភិតភ័យមិនតិច ព្រោះឃើ[…] គេសំពះកាំភ្លើងខ្លីនៅចង្កេះ ហើយមានកងការពារម្នាក់កាន់កាំភ្លើ[…] អាកាស្ស័យចត់ដើរតាមពីក្រោយ ។ នាងយល់ថា គេមិនមែនជាអ្ន[…] មានឋានៈតូចតាចឡើយ ។

ជននោះដើរមកដល់ឃើញសម្ផស្សក៏ងាកបោះជំហានចូល ហើយ[…] ចាប់ពោលឡើងធ្វើដូចជាភ្ញាក់ :

- អុំ... មានមិត្តនារីនៅទីនេះ !

- ចាស... ( សម្ផស្សបន្ទរាចាតប ដោយសង្រួមកាយវាចា[…] គោរពគេ ) ។



- នារី នៅសម្រាកឯងម្នាក់ឯង មិនចេញទៅធ្វើការទេ ?

- ចាស គ្រុន...

បរសនេះ ចាប់ប្រាកដខ្សែភ្នែក មើលមុខនាងសម្ផស្សចង្អិត[…] ទីបគេដកដង្ហើមវែង ស្ងៀមនៅមួយភ្លែត ពុំនាំឲ្យនាង ។ ឯ[…] ការពាររបស់គេ អង្គុយចុះខ្លួន និង សម្លឹងរោងនៅខាងក្រៅ ។ […] សរសើរភាពក្នុងរោងស្នាក់អាស្រ័យ របស់ក្រុមនារីចល័ត […] មួយសន្ទុះមើលជាក់មកមើលមុខនាងសម្ផស្សម្ដងទៀត សួរបញ្ជាក់ថា:

- នារីគ្រុនប៉ុន្មានថ្ងៃហើយ ?

- ចាស ពីរថ្ងៃហើយ

- គ្រុនអញ្ចឹង មិត្តនិងប្រធានកងចល័ត និង ប្រធានក្រុមនារីបាន[…] យកចិត្តទុកដាក់សួរសុខទុក្ខ ឬ មើលមិត្តនារីទេ ?

តាមការពិតក្នុងរយៈកាលពីរថ្ងៃ ដែលនាងសម្ផស្សមានជម្ងឺគ្រុនក្ដៅនេះ ប្រធានកងចល័ត ពុំដែលបានមកអើតមើលសាកសួរនាងទេ […] ថែមទាំងសម្ផស្សរិះគន់ទេ ខ្លាចខូចឥទ្ធិពលរបស់គេ និង ខ្លាចមានបញ្ហា[…] ក្រក់ដល់រូបនាងទៅថ្ងៃក្រោយ នាងក៏ឆ្លើយថា:

- ចាស ... មាន ... គាត់ដឹងថាខ្ញុំឈឺ ហើយបានអនុ - ញ្ញាតឲ្យខ្ញុំឈប់សំរាក ...

ជននង្គការនោះ ដេញដោលសួរតទៅទៀត :

- ចុះពេទ្យប្រចាំកងចល័តនេះ មានមកពិនិត្យព្យាបាលមិត្តទេ ?

- ចាស ពេទ្យបានមកឲ្យថ្នាំខ្ញុំម្ដងដែរ ។

- ពេទ្យឲ្យថ្នាំអ្វី មិត្តនារី ?

សម្ផស្សធ្ងើបក្បាលងើបមួយសន្ទុះ ដោយនាងកំប្រាប់ឈ្មោះថ្នាំមិនត្រូវ នាងឆ្លើយទាំងប្រថុយ :

- ចាស ខ្ញុំមិនស្គាល់ថ្នាំនោះដែរ ... ឃើញឲ្យថ្នាំស្ទូនពីសំបកឈើចំនួនមួយចុកដែលទុកឲ្យខ្ញុំលេបម្ដងដប់គ្រាប់ ...

- ពេទ្យមានប្រើថ្នាំអីទៀត ?...

- ចាស ឃើញមានថ្នាំទឹកពណ៌ស និង ពណ៌ក្រហមលាក់ដបទឹកក្រូច... គាត់ចាក់ដែនឲ្យខ្ញុំបានម្ដងដែរ ..

- ឥឡូវនេះ មិត្តនារីបានធូរស្រាលក្នុងខ្លួនខ្លះទេ ?

សម្ផស្សនៅក្ដៅខ្លួនគគុក កំពុងឈឺក្បាលម៉ោក ៗ តែនាងគិតថាបើឆ្លើយមិនស្រួល ជាឯងវាយប្រហារពេទ្យរបស់គេ ។

- ចាស ថ្ងៃនេះបានធូរបន្តិច តែមិនទាន់ជាទេ ...

បុរសងាកទៅបើកសំពៀត លូកដៃរាវរកឱសថ ព្រមទាំងនិយាយបណ្ដើរ :

- ខ្ញុំមានថ្នាំវិទ្យាសាស្ត្រខ្លះជាប់តាមខ្លួន សំរាប់ការពារ ជម្ងឺគ្រុនរបៀបនេះ ... ហាក៎ ! មិត្តនារីយកអាស្ពីរីនបួនប្រាំគ្រាប់ទុកលេបទៅ!

សម្ផស្សមានទម្លាប់តាមគេ ហៅមេដឹកនាំក្នុងកងទ័ពថាមិត្តបង ៗ ពេលនោះនាងក៏ឆ្លើយតបទៅបុរស :



- ចាស អរគុណមិត្តបង !

ជំនួននេះ មានវ័យប្រមាណសែសិបប្រាំ ឬ សែសិបប្រាំមួយឆ្នាំទៅហើយ តាំងពីគេឡើងឋានៈជាគណៈអភិបាលដឹកនាំទៅអង្គភាពមួយរបស់ខ្លួនមក បរិវារជនទៅជុំវិញនិយមហៅថា " លោកតា ៗ " ។ ពាក្យ " តា " នេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេហៅសំដៅអង្គការមានតួនាទីឋានៈខ្ពស់ ឯអ្នកនៅក្មេងគេច្រើនហៅ " មិត្តបង " ។ ពេលឮយុវនារីមានសម្រស់ហៅមិត្តបងដូច្នោះ បុរសញញឹមត្រេកអរឡើងឈាមមិនតិច ។ បុរសចន្លើតតូចងាកមើលទៅលើផ្ទាំងជាំងផ្ទៃងដេករបស់សម្ផស្ស រួចពោលឡើងថា :

- មិត្តនារីអើ ... មួកស្លឹកត្នោតរបស់អ្នកណាព្យួរនៅផ្ទាំងនោះមានជាហោចស្អាតណាស់ហ្ន៎ !

- ចាស មួករបស់ខ្ញុំ ។

- មួកនេះ នារីដេរខ្លួនឯង ឬ បានពីណាមក ?

- ចាស ខ្ញុំដេរ ...

- ហ៎ា នារីចេះដេរមួកស្អាតណាស់ ឲ្យខ្ញុំសុំវាទុកជាអនុស្សាវរីយ៍ទៅណ៎ានារី ។

សម្ដីរបស់អង្គការគេពេលនោះ មានទឹកមាត់ប្រៃល្វីងខ្លាំងណាស់ ពាក្យថាសុំ ឬ ស្នើ មិនខុសអំពីការបញ្ជា ឬ រឹបអូសយកទេ ។ នាងសម្ផស្សទាល់គំនិតមិនដឹងគិតយ៉ាងម៉េចក៏ផាត់ចិត្តឆ្លើយ :

- ចាស ! . . អញ្ជើញយកទៅប្រើប្រាស់ចុះ

នាងទាញម្ជុលប្រគល់ជូន បុរសយកម្ជុលលើកពាក់លើ... ឈាន់មាត់ :

- យីត្រូវល្មមតែម្តង ! ( គេក្រោកឡើងយកតែស្ពាយលាក់ក... ខ្ញុំនឹងទាញខ្សែក្រវាត់ឡើងទឹមចង្កេះ រួចពោលទៅកាន់ថាណារីទៀ... មុខញញឹម ) : ខ្ញុំលាសិនហើយណាំនារី . . . មិនអីទេ ! ... ត្រូវលខ្ទង-នៅសំរាកឱ្យទាល់តែជាថែនថែនទៅណាំ កុំទៅធ្វើការ... ឈឺ ចាំខ្ញុំប្រាប់មិត្តជិនប្រធានកងចល័ត ឱ្យជួយមើលថែរក្សាការពារ... ភាពមិត្តនារីឱ្យបានជិតដល់ . . . លាហើយណាំ ។

- ចាស . . .

គេនាំគ្នាការពារបោះជំហានដើរចេញទៅ ។ នាងសម្ផស្ស... គិតពិចារណាម្នាក់ឯងថា ថ្ងៃនេះភ័ព្វវាសនាអ្វីកើតឡើងចំពោះ រូបនាង ? តាមធម្មតាអ្នកឈឺកន្លងមកច្រើនតែត្រូវគេពិនិត្យតាមដាន ហើយកទៅកសាង ឬ ធ្វើការងារសតិអារម្មណ៍ ខ្លះគេនិយាយចំអក ជំទយថាគ្រូនទន្សាយបាយបាន . . . ខ្លះទៀតត្រូវគេចិញ្ចៀនព្រមានថា ជាមនុស្សខ្ជិលច្រអូស គេចវេះពីការងារពលកម្ម . . . នៅផាប់កំផែល សក្តិភូមិនាយទន . . . ឯរូបនាងពេលនេះ បែរជាត្រូវអង្គការគេយក ចិត្តទុកដាក់ហួសពីការនឹកស្មានទៅវិញ ។



... អាចនិយាយបានថា ដោយសារថ្នាំពេទ្យដែលគេបាន ចបន្តិចនោះ រួមផ្សំនឹងបរិយាកាសអំណោយផល បីបួនថ្ងៃ មក នាងសម្ផស្សក៏បានជាសះស្បើយឡើងវិញ ។ នាងបាន ធ្វើពលកម្មជាមួយមិត្តយុវជន-នារីក្នុងកងចល័តជាធម្មតា ។ ...ឃើញបងមានសុខភាពអាចធ្វើការបានឡើងវិញ នាងក្រេកអរ នាងលើកដីផង និយាយលេងពេញជាមួយគេផង ។

...សាប់តែថ្ងៃនេះ មិត្តជិនប្រធានកងចល័តបានឱ្យប្រធានក្រុម ហៅនាងសម្ផស្សចេញពីការដ្ឋាន កណ្តាលថ្ងៃជាក់ស្តៀល ... ...ហៅមកទៅជួបនឹងមិត្តជិននៅរោងចាត់ការកងចល័ត ។

មិតសម្ផស្សចូលម៉ោ ! ( មិត្តជិនពោលឡើង ) ខ្ញុំមានការ ...និងមិត្តបន្តិច !

...ពីចលកងចល័តមក សម្ផស្សខ្លាចមិត្តជិនដូចខ្លាចខ្លា ព្រោះ ...ជាមនុស្សមានឫកពារកោងកាច សម្តីអាក្រក់ និយាយម៉ាត់ ...ហ្នឹង មិនសូវចេះយោគយល់ដល់យុវជនផងគ្នាទេ ។ ជិនជា ...នទើបនឹងរៀនចេះអក្សរបន្តិចបន្តួច ប៉ុន្តែការដែលគេត្រូវបាន ...តាំងជាប្រធានកងចល័តនេះ គឺដោយសារគេជាមនុស្សស្ថិត ...ណ្ណៈស្រទាប់បាត "១" ។ តែតាំងពីថ្ងៃមានអង្គការស្រុក ...ការដ្ឋាននោះ មិត្តជិនមានការប្រែប្រួលអាកប្បកិរិយាខ្លះ ៗ ។

១ " វណ្ណៈក្រីក្របំផុត

នាងសម្ផស្សចន្ទីវាចារតបទៅវកផិនវិញទាំងការភិតភ័យបារម្ភ :

— ចាស មិត្តប្រធានហៅខ្ញុំ មានការអី ឬ ?

— មានការផ្ទាល់ខ្លួននារីឯងណា ! អង្គការស្រុកបានប្រើទារសា

យកសំបុត្រមួយនេះមកឱ្យខ្ញុំ . . . ។ សំបុត្រនេះនែ !

ផិនទាញហូតលិខិតមួយពីហោប៉ៅអាវមក ពិនិត្យមើលម្តងទៀត តែ ដោយមិនបានគិតគេលាសំបុត្របញ្ហោសអក្សរ ។ លុះដឹងខ្លួន ផិនក៏ ប្រគល់ឱ្យប្រធានក្រុមនារីមើលម្តង ។ ប្រធានក្រុមនារីអានតិច ៗ :

> មកដល់មិត្តផិនប្រធានកងចល័ត ឃុំព្រៃឃ្នេស !
>
> ផ្អែកតាមការឯកភាពរបស់សមមិត្តលេខាបក្សគណៈស្រុកមេសាង ស្នើសមមិត្តចាត់បញ្ជូននារីសម្ផស្ស ដែលនៅក្នុងកងចល័តរបស់សមមិត្តឡើងមកគណៈមន្ទីរសន្តិសុខស្រុកក្នុងថ្ងៃនេះព្រោះមានការចាំបាច់ផ្ទាល់ខ្លួន ។
>
> ថ្ងៃទី ១៥ ខែ ៣ ឆ្នាំ ១៩៧៧
>
> ហត្ថលេខា
>
> សមមិត្ត ម៉ាន់

ប្រធាននារីអានហើយ ងើបមើលមុខសម្ផស្ស ពោលបញ្ជាក់ ប្រាប់ថា :

— អ្ហឺ ! សំបុត្រនេះ អង្គការហៅមិត្តសម្ផស្សឯងទៅកន្លែងស្រុក ឥឡូវនេះ ។

សម្ផស្សបោចពោះភិប ៗ ធ្លាក់ទឹកមុខស្លុត រំពេច :

— ឱ្យខ្ញុំទៅកន្លែងអង្គការនៅស្រុក . មានការអ្វីហ្នឹងមិត្តបង?

— មិនបាច់នារីឯងសួរដឹងឫសគល់ទេ មិត្តផិនឆ្លើយតប អង្គការ មានការហើយ បានជាហៅមិត្តឯងទៅ !

សម្ផស្សឱនមុខចុះ ចាប់ស្ទើតស្ទាំងគាំងស្មារតី គិតនៅក្នុង សភាពស្លុតស្លៀមគសរយៈកាលដ៏យូរ ។ ផិននិងប្រធានក្រុមនារី មើលមុខគ្នាទៅវិញ ដោយមិនយល់ពីកិច្ចការអាថ៌កំបាំងរបស់អង្គការគេ ដែរ ។ ប្រធាននារីបោះសម្តីសួរសម្ផស្ស :

— មេចក៏ សម្ផស្សនៅអង្គុយស្ងៀមអីទៀត ?

— ចាស ខ្ញុំមិនទៅទេ ព្រោះខ្លាចនៅឆ្ងាយពួកមិត្តយើងក្នុងកង ចល័តនិងធ្លាប់នៅជាមួយមិត្តបង . . .

— មិនមែនបានរឿងមិត្តឯងចង់ឬមិនចង់ទេ ! នេះជាបញ្ជារបស់អង្គ-ការ ! ព្រោះអង្គការមានការប្រញាប់ណាស់ បានជាហៅមិត្តឯងទៅ ជាបន្ទាន់ ! ទៅរៀបចំខ្លួនទៅ !

សម្ផស្សរកពាក្យប្រកែកមិនបាន ក៏ឆ្លើយទទួលទាំងការតឹងតែងចិត្ត :

— ចាស ខ្ញុំទៅតាមបញ្ជា . . . តែខ្ញុំសុំអនុញ្ញាតពីមិត្តបង ទៅជួប ភារីប្អូនរបស់ខ្ញុំមួយភ្លែត ។